# ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹង
## នៅក្នុងខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៚

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ-ក្រសួងបរិស្ថាន

លេខ : ៨០ ប្រក.មផ - បស្ថ

# ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន

## ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រមក/ ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤ /២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦ /៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

ប្រការ ១ : ប្រកាសនេះមានគោលបំណង ជំរុញកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវវិធានការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន សំដៅធានាបាននូវកិច្ចការពារសុខភាពសាធារណៈ សោភ័ណភាព គុណភាពបរិស្ថាន និងជីវចំរុះ ។

ប្រការ ២ : ប្រកាសនេះមានវិសាលភាពអនុវត្តទៅលើរាល់សកម្មភាពប្រមូល សំអាត ស្តុកបណ្តោះអាសន្ន ដឹកជញ្ជូន កែច្នៃ បោះចោលសំរាម សំណល់រឹងគ្រប់ប្រភេទ នៅតាមខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : និយមន័យ

ក- សំរាម សំណល់រឹង សំដៅទៅលើវត្ថុ ឬរបស់ដែលសល់ពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ឬដែលសល់ ឬកើតពីសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម និងផលិតកម្ម ហើយដែលវត្ថុ ឬរបស់សល់ទាំងនោះមិនមានផ្ទុកជាតិពុល ឬមិនបង្កឱ្យមានជាគ្រោះថ្នាក់ ។

ខ- អាជ្ញាធរដែនដី សំដៅទៅលើអាជ្ញាធរថ្នាក់ខេត្ត ក្រុង ថ្នាក់ខ័ណ្ឌ ស្រុក ថ្នាក់ឃុំ សង្កាត់ ។

គ- ទីបរិវេណ សំដៅទៅលើលំនៅដ្ឋាន អាគាររដ្ឋបាលសាធារណៈ រោងចក្រ សិប្បកម្ម ទីសត្តឃាត សណ្ឋាគារ ភោជនីយដ្ឋាន ។

### ជំពូក ២

### ការគ្រប់គ្រងការចោលសំរាម សំណល់រឹងរាយប៉ាយ

ប្រការ ៤ : ការបោះចោល ឬចាក់ចោលសំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវ ទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកំសាន្ត មណ្ឌលទេសចរណ៍ រមណីយដ្ឋាន បូជនីយដ្ឋាន ទីវាលស្រែចំការ តំបន់ការពារ តំបន់ព្រៃភ្នំ តំបន់ឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ផ្លូវនាវាចរ ប្រព័ន្ធបង្ហូរទឹកកខ្វក់ ប្រព័ន្ធប្រឡាយកសិកម្ម ត្រូវហាមឃាត់ជាដាច់ខាត ។

ប្រការ ៥ : អាជ្ញាធរដែនដីត្រូវទទួលខុសត្រូវ និងចាត់វិធានការចាំបាច់មួយចំនួន ដើម្បីរាំងនិងបញ្ឈប់ការចោលសំរាម សំណល់រឹងរាយប៉ាយនៅតាមទីកន្លែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដូចមានចែងនៅក្នុងប្រការ ៤ ខាងលើ រួមមាន :

ក រៀបចំដាក់ធុងសំរាមសាធារណៈឱ្យបានគ្រប់គ្រាន់ ធានាបាននូវសោភ័ណភាព និងបរិស្ថានស្អាត ។

ខ រៀបចំដាក់ផ្លាកសញ្ញាហាមឃាត់ និងអប់រំពីការទុកដាក់និងបោះចោលសំរាម សំណល់រឹង ។

គ កំណត់ និងរៀបចំកន្លែងស្តុកសំរាម សំណល់រឹងបណ្តោះអាសន្ន អោយបានសមស្របដោយមិនបង្កបញ្ហាដែលនាំឱ្យប៉ះពាល់ដល់ការធ្វើចរាចរ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម ។

ឃ ធ្វើការប្រមូល សំអាត និងដឹកជញ្ជូនសំរាម សំណល់រឹងទាំងនោះយកទៅចាក់ចោលនៅទីតាំងដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរដែនដី អោយបានទៀងទាត់ជាប្រចាំ ។

## ជំពូក ៣
## ការគ្រប់គ្រងសំរាម សំណល់រឹងតាមទីបរិវេណ

ប្រការ ៦ : អាជ្ញាធរដែនដីត្រូវទទួលខុសត្រូវ និងអនុវត្តការប្រមូល ការស្តុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោលសំរាម សំណល់រឹង នៅតាមទីបរិវេណតាមវិធីខាងក្រោម :

ក រៀបចំសេចក្តីណែនាំពីការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទាំងនោះសំរាប់ការស្តុកបណ្តោះអាសន្ន និងការប្រមូល ។

ខ កំណត់កម្មវិធីប្រមូលឱ្យបានសមស្រប និងធ្វើការប្រមូលឱ្យបានអស់ ស្អាត និងទៀងទាត់ ។

គ ត្រួតពិនិត្យការដឹកជញ្ជូនសំរាម សំណល់រឹងខាងលើ ដើម្បីជៀសវាងការធ្លាក់រាយប៉ាយតាមដងផ្លូវ ដែលនាំឱ្យមានការប៉ះពាល់ដល់ការធ្វើចរាចរ និងសោភ័ណភាព ។

/

ប្រការ ៧ : សំរាម សំណល់រឹងដែលប្រមូលពីប្រភពដូចមានចែងក្នុងប្រការ ៦ ខាងលើ ត្រូវយកទៅចាក់នៅរណ្តៅ ឬទីលានចាក់សំរាម ដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរដែនដី ។

ការចាក់ចោលសំរាម សំណល់រឹង នៅក្នុងទីបរិវេណ ឬដីកម្មសិទ្ធិឯកជនក្នុងគោលបំណងណាក៏ដោយ ត្រូវហាមឃាត់ជាដាច់ខាត ។

## ជំពូក ៤

## ការគ្រប់គ្រងទីលានចាក់សំរាម សំណល់រឹង

ប្រការ ៨ : អាជ្ញាធរដែនដី :

ក ករណីតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ពុំទាន់មានរណ្តៅសំរាប់ចាក់សំរាម សំណល់រឹង ត្រូវធ្វើការកំណត់និងរៀបចំទីលាន ឬរណ្តៅចាក់សំរាម សំណល់រឹង ដោយត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការកាត់បន្ថយការបំពុលបរិស្ថាន និងការប៉ះពាល់សុខភាពសាធារណៈ អនុលោមតាមគោលការណ៍ណែនាំបច្ចេកទេសនៃក្រសួងបរិស្ថាន និងសូមគោលការណ៍អនុញ្ញាតក្នុងការកំណត់ទីតាំងជាមុនពីក្រសួងមហាផ្ទៃ ។

ខ ករណីតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន មានទីលាន ឬរណ្តៅចាស់កំពុងដំណើរការប្រើប្រាស់ ត្រូវធ្វើការជំរុញដំណើរការ និងការថែទាំឱ្យមានលក្ខណៈកាន់តែល្អប្រសើរ និងត្រូវធ្វើការត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំ ។

គ ករណីតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ដែលរណ្តៅចាស់មានសភាពពេញហៀរ ឬមិនអាចទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ជាបន្ត ត្រូវរៀបចំកម្មវិធីបញ្ឈប់ ការប្រើប្រាស់រណ្តៅ ឬទីលានចាក់នោះ ដោយមិនបង្កការរាំងស្ទះដល់ការចាក់ចោលសំរាម សំណល់រឹងដែលកំពុងដំណើរការ និងកំណត់នូវកម្មវិធីគ្រប់គ្រងនិងស្តារទីលានចាស់ ដែលឈប់ប្រើនោះឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ។

ប្រការ ៩ : ការដុតសំរាម សំណល់រឹងគ្រប់ប្រភេទ ទោះស្ថិតក្នុងទីលាន ឬរណ្តៅចាក់សំរាម សំណល់រឹងក្តី ត្រូវហាមឃាត់ជាដាច់ខាត ។

ប្រការ ១០ : ហាមឃាត់ជាដាច់ខាតចំពោះការប្រមូល ការដឹកជញ្ជូន និងការបោះបង់ចោលសំរាម សំណល់រឹង ដោយមានការលាយបញ្ចូលសំណល់រឹងពុល ឬប្រកបដោយគ្រោះថ្នាក់ ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

## ជំពូក ៥
## ភារៈកិច្ចរបស់អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ និងការចូលរួមពីសាធារណៈជន

ប្រការ ១១ : មន្ទីរបរិស្ថានខេត្ត ក្រុង និងការិយាល័យបរិស្ថានខណ្ឌ ស្រុក ត្រូវបំពេញភារកិច្ចជាសេនាធិការឱ្យអាជ្ញាធរដែនដីក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមធ្វើផែនការសកម្មភាពក្នុងការប្រមូល ស្តុកទុកបណ្តោះអាសន្ន ដឹកជញ្ជូន និងបោះចោលសំរាម សំណល់រឹង ហើយត្រូវចូលរួមសហការ និងត្រួតពិនិត្យការអនុវត្តន៍នោះ ។

ប្រការ ១២ : អាជ្ញាធរដែនដីដោយមានមន្ទីរបរិស្ថានខេត្ត ក្រុង ជាសេនាធិការ ត្រូវធ្វើរបាយការណ៍ពីសកម្មភាពអនុវត្តរបស់ខ្លួនលើការប្រមូល ការស្តុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោលសំរាម សំណល់រឹង រៀងរាល់ត្រីមាស ហើយត្រូវផ្ញើរបាយការណ៍នោះមកក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ព្រមទាំងចំលងជូនទៅស្ថាប័នពាក់ព័ន្ធ ។

ប្រការ ១៣ : អាជ្ញាធរដែនដី សំខាន់គឺ ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការចូលរួមសហការពីស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ត្រូវធ្វើការអប់រំនិងផ្សព្វផ្សាយជូនដល់គ្រប់ប្រជាពលរដ្ឋពីការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងតាមវិធីប្រកបដោយអនាម័យសុវត្ថិភាពបរិស្ថាន ។

ក្នុងគោលបំណងកាត់បន្ថយបរិមាណនៃការចាក់ចោលសំរាម សំណល់រឹង ត្រូវធ្វើការជំរុញ និងលើកទឹកចិត្តដល់សកម្មភាពទាញយកមកប្រើប្រាស់ឡើងវិញ ឬកែច្នៃនូវសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ប្រការ ១៤ : ប្រជាពលរដ្ឋគ្រប់រូប ត្រូវមានកាតព្វកិច្ចចូលរួមយ៉ាងសកម្ម ក្នុងការថែទាំអនាម័យលំនៅដ្ឋាន និងជុំវិញលំនៅដ្ឋាន សោភ័ណភាពទីសាធារណៈ ឬទីប្រជុំជននៃខេត្ត ក្រុង គុណភាពបរិស្ថាន និងត្រូវចូលរួមយ៉ាងសកម្មក្នុងការការពារ និងថែទាំធុងសំរាមសាធារណៈ ។

//

ប្រការ ១៥ : អគ្គនាយកដ្ឋានបច្ចេកទេសក្រសួងបរិស្ថានត្រូវ :

ក ទទួលខុសត្រូវក្នុងការផ្តល់នូវគោលការណ៍ណែនាំបច្ចេកទេសសំរាប់ជំរុញការអនុវត្តនី ការប្រមូល ការស្តុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោល សំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

ខ សហការជាមួយស្ថាប័នពាក់ព័ន្ធ ចុះពិនិត្យ និងវាយតំលៃលើការអនុវត្តន៍សេចក្តីប្រកាសនេះ ដើម្បីរាយការណ៍ជូនក្រសួងមហាផ្ទៃនិងក្រសួងបរិស្ថាន ដើម្បីពិនិត្យ ផ្តល់ការសរសើរលើកទឹកចិត្ត ឬធ្វើការព្រមាន ក្នុងករណីពុំអនុវត្តតាមសេចក្តីប្រកាសនេះ ។

## ជំពូក ៦

## ទោសទណ្ឌ

ប្រការ ១៦ : ជនណាដែលប្រព្រឹត្តល្មើសនឹងប្រការ ៤ ប្រការ ៦ ប្រការ ៨ និងប្រការ ៩ នៃសេចក្តីប្រកាសនេះ ត្រូវទទួលការពិន័យជាប្រាក់ពី ១០.០០០ រៀល ទៅ ១០០.០០០ រៀល ។ ក្នុងករណីមិនរៀងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេរដង ។

## ជំពូក ៧

## អវសានបញ្ញត្តិ

ប្រការ ១៧ : អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងបរិស្ថាន អគ្គនាយកបច្ចេកទេសនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងបរិស្ថាន អភិបាលខេត្ត ក្រុង នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាននៃក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ ការិយាល័យបរិស្ថានខណ្ឌ ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលអនុវត្តសេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធិភាព ។

ប្រការ ១៨ : ប្រកាសនេះមានអនុភាពជាគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៣

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

បណ្ឌិត ម៉ុក ម៉ារ៉េត

ចំលងជូន :

- ខុទ្ទការល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាតិ
- អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- គ្រប់ក្រសួង ស្ថាប័ន

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ១៧

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# ប្រកាស

## ស្តីពី

# ក្របខណ្ឌសមត្ថកិច្ចរបស់ នាយកគ្រប់គ្រងឧទ្យានជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងគ្រប់គ្រងបរិស្ថាន

លេខ: 145 ប.ស្ស.

រាជធានីភ្នំពេញ ថ្ងៃទី 25 ខែ 01 ឆ្នាំ១៩៩6

# ប្រកាស
## ស្តីពី
## ក្របខ័ណ្ឌសមត្ថកិច្ចរបស់ នាយកគ្រប់គ្រងឧទ្យានជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល.
- បានឃើញព្រះរាជក្រឹត្យរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ.
- យោងសេចក្តីត្រូវការចាំបាច់នៃការងារ.

## សំរេច

**ប្រការ១** : បង្កើតក្របខណ្ឌ័ និងសមត្ថកិច្ចគ្រប់គ្រងឧទ្យានជាតិ ដែលមានរចនាសម្ព័ន្ធ ដូចខាងក្រោម: ឧទ្យានជាតិនីមួយៗ ស្ថិតនៅក្រោមការដឹកនាំរបស់នាយកមួយរូបនិងនាយករងមួយរូបយ៉ាងតិច និងចែកចេញជាពីរផ្នែក :
- ផ្នែកទទួលបន្ទុករដ្ឋបាល
- ផ្នែកទទួលបន្ទុកបច្ចេកទេស

**ប្រការ២** : នាយក នាយករងឧទ្យានជាតិ ក្នុងតំណែងមានឋានានុក្រម ស្មើនឹងប្រធាន អនុប្រធានការិយាល័យ ក្រសួងបរិស្ថាន ។

Nat.\Prokas1

**ប្រការ៣** : ក្របខណ្ឌ និងសមត្ថកិច្ចគ្រប់គ្រងឧទ្យានជាតិ ស្ថិតនៅក្រោមនិវាទនាយកដ្ឋានគ្រប់គ្រងឧទ្យានជាតិ និងប្រពន្ធ័ការពារធម្មជាតិ នៃក្រសួងបរិស្ថាន ។

**ប្រការ៤** : កិច្ចការពាក់ពន្ធ័នឹងសមត្ថកិច្ចអាជ្ញាធរខេត្ត ក្រុង ត្រូវធ្វើឡើងតាមរយៈមន្ទីរបរិស្ថានប្រចាំខេត្ត-ក្រុង ។

**ប្រការ៥** : តួនាទី និងភារកិច្ចរបស់នាយកឧទ្យានជាតិ រួមមាន:

៥.១- ដឹកនាំការងារ លើកគំរោង ធ្វើផែនការ សិក្សាស្រាវជ្រាវ ការពារអភិរក្ស និងអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាពឧទ្យានជាតិ ។

៥.២- រក្សាការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងតំបន់ឧទ្យានជាតិ.

៥.៣ ក្នុងក្របខណ្ឌនៃប្រការ ៣ នាយកឧទ្យានជាតិ ទទួលសិទ្ធិធ្វើសហប្រតិបត្តិការជាទ្វេភាគី ឬពហុភាគីជាមួយអង្គការជាតិ និងអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស និងទទួលជំនួយសំភារៈ ថវិកាសំរាប់ធ្វើការអភិរក្ស សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ឧទ្យានជាតិ ។

៥.៤- ធ្វើអន្តរាគមជាមួយស្ថាប័នពាក់ពន្ធ័ និងរដ្ឋអំណាចមូលដ្ឋាន ក្នុងការការពារបូរណភាពឧទ្យានជាតិ ។

**ប្រការ៦** : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងឧទ្យានជាតិ និងប្រពន្ធ័ការពារធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង នាយកឧទ្យានជាតិនីមួយៗ ត្រូវមានភារកិច្ចអនុវត្តសេចក្ដីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បណ្ឌិត ម៉ុក-ម៉ារ៉េត

ចំលងជូនៈ

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី២
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងទេសចរណ៍
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ
- អភិបាលខេត្ត-ក្រុងពាក់ពន្ធ័
- មន្ទីរបរិស្ថានខេត្ត-ក្រុងពាក់ពន្ធ័
- ដូចប្រការ៦ "ដើម្បីសហការអនុវត្ត"
- កាលប្បវត្តិ-ឯកសារ.

Nat.\Prokas1

# ប្រកាស

## ស្តីពី

## ការបង្កើតយន្តការតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ និង ការបំបាត់ភាពអនាធិបតេយ្យ ក្នុងវិស័យព្រៃឈើ និងតំបន់ការពារធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: 429 ប.ស្ថ. ប្រក

ក្រសួងបរិស្ថាន
នាយកដ្ឋានការពារ.អភិរក្ស.ធម្មជាតិ
ចូល លេខ ........B.ធ.បស្ថ
ថ្ងៃទី 12 ខែ 4 ឆ្នាំ 99

រាជធានីភ្នំពេញ ថ្ងៃទី 24 ខែ 3 ឆ្នាំ ១៩៩៩

# ប្រកាស

## ស្តីពីការបង្កើតយន្តការតាមដានឃ្លាំមើល បទល្មើសក្នុងវិស័យព្រៃឈើ និងការបំបាត់ ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ និងតំបន់ការពារធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស.រកម .១២៩៦.០៦ ចុះថ្ងៃទី ធ្នូ ១៩៩៦ ដែលប្រកាស អោយ ប្រើច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ ប្រក ចុះថ្ងៃទី ២៥ មករា ១៩៩៩ ស្តីអំពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

- បានឃើញសេចក្ដីជូនដំណឹង លេខ ២២៨ សជណសរ ចុះថ្ងៃទី ២៣ កុម្ភៈ ឆ្នាំ ១៩៩៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

## <u>សំរេច</u>

<u>ប្រការ១</u>: បង្កើតយន្តការមួយដើម្បីធ្វើការតាមដានឃ្លាំមើលបទល្មើស លើវិស័យព្រៃឈើនៅក្នុង ព្រះរាជាណាចក្រកម្ពុជា មានឈ្មោះថា "ភ្នាក់ងារតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ" ។

<u>ប្រការ២</u>: ប្រគល់ភារកិច្ចបន្ថែមជូននាយកដ្ឋានអធិការកិច្ចទទួលអនុវត្តយន្តការនេះរួមមានការតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ និង តំបន់ការពារធម្មជាតិ ។

<u>ប្រការ៣</u>: នាយកដ្ឋានអធិការកិច្ចបំពេញមុខងារពង្រីកបន្ថែមដូចតទៅ :

- គ្រប់គ្រង និងកំណត់វាយតំលៃលាស់ពិតប្រាកដនូវពតិមានស្ដីពី សកម្មភាព អនាធិបតេយ្យ ក្នុងវិស័យ ព្រៃឈើ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងបរិស្ថានពិនិត្យសំរេច ។
- សហការជាមួយនាយកដ្ឋាននៃក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត-ក្រុង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ ព្រមទាំង អង្គការក្រៅរដ្ឋាភិបាលក្នុង និង ក្រៅប្រទេស ដើម្បីធានានូវភាពទទួលខុសត្រូវចំពោះ តួនាទីរបស់ខ្លួន ។
- ត្រូវធ្វើរបាយការណ៍ជាប្រចាំ ស្ដីពីសកម្មភាពរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន ។

<u>ប្រការ៤</u>: ប៉ុស្តិ៍របស់ភ្នាក់ងារតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ នៃក្រសួងបរិស្ថាន ស្ថិតនៅក្នុង តំបន់ការពារធម្មជាតិ ដែលបានប្រកាសដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ។

ប្រការ៥: ការរៀបចំផ្ទៃក្នុងនៃអង្គភាពខាងលើ ដូចមានចែងក្នុងប្រការ ១ ជាសមត្ថកិច្ច របស់ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន ។

ប្រការ៦ : មូលនិធិសំរាប់ទ្រទ្រង់ការអនុវត្តភារកិច្ច តាមដានឃ្លាំមើលបទល្មើស ក្នុងវិស័យព្រៃឈើ ត្រូវបានមកពីថវិការដ្ឋ ពីប្រភពស្របច្បាប់ផ្សេងៗ និង ជំនួយពី អង្គការអន្តរជាតិនានា ។

<u>ប្រការ៧</u> : ការគ្រប់គ្រង និង ការប្រើប្រាស់មូលនិធិ ក្នុងកិច្ចដំណើរការពាមដានឃ្លាំមើលបទល្មើស ក្នុងវិស័យព្រៃឈើត្រូវសំរេច ដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និង ស្របតាមច្បាប់ហិរញ្ញវត្ថុ ។

<u>ប្រការ៨</u>: អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានអធិការកិច្ច គ្រប់នាយកដ្ឋាន ចំណុះក្រសួងបរិស្ថាន និង មន្ទីរបរិស្ថានខេត្តក្រុង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។ ៨

ម៉ុក ម៉ារ៉េត

<u>ចំលងជូន</u> :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៨ "ដើម្បីអនុវត្ត"

-ឯកសារ. និងកាលប្បវត្តិ

# សេចក្តីប្រកាស

# ស្តីពី

# វិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
ចូល លេខ: 15.9.7..19
ថ្ងៃ 8 ... 10 ... 99

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩

ក្រសួងបរិស្ថាន
នាយកដ្ឋានការពារ.អភិរក្ស.ធម្មជាតិ
ចូល លេខ........13.5....ធ.បល្ក
ថ្ងៃទី..17....ខែ.02....ឆ្នាំ.2000

# សេចក្តីប្រកាស
## ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ
## ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី

* * * * *

ដោយពិនិត្យឃើញថា ទោះបីមានគោលនយោបាយ ស្តីពីការគ្រប់គ្រង និងប្រើប្រាសដីធ្លី ច្បាប់ភូមិបាលឆ្នាំ ១៩៩២ និងលិខិតបទដ្ឋានជាច្រើនទៀតដែលរាជរដ្ឋាភិបាល បានដាក់ចេញជាបន្តបន្ទាប់ សំដៅពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងប្រើប្រាស់ដីធ្លីអោយបានចំទិសដៅ ក៏នៅតែមានជនខិលខូចមួយចំនួនបាននិងកំពុងឆ្លៀតឱកាសឥតឈប់ឈរបង្កនូវភាពអនាធិបតេយ្យរានទន្ទ្រានយកដីធ្លី ក្រោមរូបភាពធ្វើជាតំបន់អភិវឌ្ឍន៍ ឬ ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បាតុភាពរានទន្ទ្រានយកដីធ្លី ដោយសង់រោង សង់ខ្ទម សង់ផ្ទះ ឬដាំដំណាំនៅលើដីរបស់រដ្ឋ អាងទឹក តំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជំរកសត្វព្រៃ ដែនបំរុង ដីចំណីផ្លូវ ទាំងផ្លូវថ្នល់ និងផ្លូវដែក ដីរបស់ក្រុមហ៊ុនវិនិយោគ ព្រមទាំងដីរបស់ឯកជន នៅតាមទីកន្លែងជាច្រើន ជាពិសេសនៅតាមបណ្តោយផ្លូវជាតិសំខាន់ៗ និងផ្លូវរថភ្លើង ។ ប្រសិនបើភាពអនាធិបតេយ្យបែបនេះនៅតែបន្តទៅទៀតនោះ វានឹងបង្កបង្កើតនូវឧបសគ្គនិងឥទ្ធិពលអាក្រក់រាំងស្ទះដល់ផែនការអភិវឌ្ឍន៍លើគ្រប់វិស័យនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ។

ចំពោះមុខបាតុភាពនេះ រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវវិធានការបន្ទាន់ដូចតទៅ :

* ១_មិនអោយមានសិទ្ធិជាឯកជនលើដីរបស់រដ្ឋ ជាអាទិ៍ ដីក្នុងដែនបំរុងរុក្ខា ដែននេសាទ អាងកំពស់ទឹកស្រោចស្រព តំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជំរកសត្វព្រៃ ដីព្រៃលិចទឹក ដីព្រៃកោងកាង ចំការព្រៃដាំ ចំការកៅស៊ូ ស្ថានីយ៍ និងមជ្ឈមណ្ឌលបច្ចេកទេសកសិកម្ម បរិវេណមណ្ឌលវ៉ៃ មណ្ឌលបេតិកភ័ណ្ឌវប្បធម៌ វត្តអារាម សាលារៀន សួនសាធារណៈ ដីបំរុង ដីចំណីផ្លូវថ្នល់ និងដីចំណីផ្លូវដែក ក៏ដូច ជាដីរបស់ក្រុមហ៊ុនវិនិយោគ និងដីរបស់ឯកជនស្របច្បាប់តាមគ្រប់រូបភាព និង[illegible]ក្នុងផ្ទៃ ប្រទេស និងបញ្ឈប់ជាបន្ទាន់សកម្មភាពរានទន្ទ្រានកាន់កាប់ដីតំបន់ដែលបានរៀបរាប់ខាងលើនេះ ព្រម ទាំងអ្វីៗ ដទៃទៀត ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ និងសម្បត្តិឯកជនរបស់រដ្ឋ ។

២_ហាមដាច់ខាត ការចេញបន្តទៀតនូវបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លី ដែលបានមកពីការរំលោភបំពានខាងលើ ព្រមទាំងមានវិធានការយ៉ាងតឹងរឹងបំផុតតាមច្បាប់ជាធរមាន ។

៣_អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការស្រាវជ្រាវជាបន្ទាន់អោយបានហ្មត់ចត់ នូវរាល់បាតុភាពភានទន្រ្ទានកាន់កាប់ដីធ្លីគ្រប់ប្រភេទដោយល្មើសច្បាប់ ដែលកើតមាននៅក្នុងទីតាំងខេត្ត-ក្រុងរបស់ខ្លួន ហើយត្រូវមានវិធានការទប់ស្កាត់ជាបន្ទាន់ដោយផ្អែកលើគោលការណ៍ច្បាប់ជាធរមាន ។

៤_បាតុភាពអនាធិបតេយ្យនេះ បើកើតឡើងនៅក្នុងទឹកដីនៃខេត្ត-ក្រុងណា គឺអាជ្ញាធរដែនដីនៃខេត្ត-ក្រុងនោះទទួលខុសត្រូវដោះស្រាយដោយស្មារតីម្ចាស់ការ ។ ប្រសិនបើជួបប្រទះការលំបាកស្មុគស្មាញ អាជ្ញាធរខេត្ត-ក្រុង ត្រូវស្នើសុំអន្តរាគមន៍ជាបន្ទាន់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដែលមានការចាំបាច់ ។

៥_អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការគ្រប់យោធភូមិភាគ និងក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ហើយត្រូវចូលរួមសហការអោយបានទាន់ពេលវេលាជាមួយអាជ្ញាធរដែនដីខេត្ត-ក្រុង តាមសំណូមពរជាក់ស្តែង ។

៦_បុគ្គល អង្គភាព ស្ថិតនៅក្រោមឱវាទរបស់ក្រសួង-ស្ថាប័នណា ឬប្រជាពលរដ្ឋណាដែលបានបង្កអោយមានសកម្មភាពអនាធិបតេយ្យ លើបញ្ហាភានទន្រ្ទានកាន់កាប់ដីធ្លី ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្រសួង-ស្ថាប័នសាមី និងអាជ្ញាធរនៅកន្លែងនោះ ត្រូវធ្វើការអប់រំណែនាំ និងជួយជំរុញអង្គភាព ឬបុគ្គលទាំងនោះអោយបញ្ឈប់សកម្មភាពល្មើសច្បាប់ ហើយតំរូវអោយគេធ្វើការស្ម័គ្រចិត្ត [illegible] បើមានការរឹងទទឹងមិនព្រមអនុវត្តតាមការណែនាំនេះទេ ក្រសួង-ស្ថាប័នអាណាព្យាបាលសាមី និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវដាក់វិន័យ ឬដកហូតមុខតំណែង និងត្រូវទទួលទោស តាមច្បាប់ជាធរមាន តាមករណីដែលបានប្រព្រឹត្ត ។

៧_ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់និងនេសាទ សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរដែនដីខេត្ត-ក្រុង ត្រួតពិនិត្យអោយបានជាក់ស្តែងលើក្រុមហ៊ុនវិនិយោគដីធ្លី និងម្ចាស់ដីធ្លីទាំងឡាយមានទំហំធំ ដែលកន្លងមកបានទទួលគោលការណ៍វិនិយោគស្របច្បាប់ជាយូរមកហើយ ប៉ុន្តែបានទុកចោលដីទំនេរពុំទាន់បានចាប់ផ្តើមដំណើរការអោយស្របទៅតាមកិច្ចសន្យានោះឡើយ ។ សមត្ថកិច្ចពាក់ព័ន្ធទាំងនោះត្រូវចាត់វិធានការម៉ឺងម៉ាត់ ដើម្បីដោះស្រាយទៅតាមច្បាប់ជាធរមាន ។

៨_កំណត់ដីចំណីផ្លូវថ្នល់ និងចំណីផ្លូវរថភ្លើងសំរាប់បំរើការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធដូចតទៅ :

_ផ្លូវជាតិមានលេខមួយខ្ទង់ ដូចជាលេខ ២,៣, ៦, ៧ ចម្ងាយ ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ លើកលែងតែផ្លូវជាតិ លេខ ១, ៤, ៥ កំណត់ចម្ងាយ ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវជាតិមានលេខពីរខ្ទង់ ដូចជាលេខ ១១,២២,៦៤,៧៨ ចម្ងាយ ២៥ម៉ែត្រពីសងខាង អ័ក្សផ្លូវ

-ផ្លូវខេត្តចម្ងាយ ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវឃុំ ចម្ងាយ ១៥ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ

ការកំណត់ចំណីផ្លូវនេះ មិនយកមកអនុវត្តក្នុងទីប្រជុំជនទេ ។

-ផ្លូវរថភ្លើងចម្ងាយ ២០ម៉ែត្រ ពីសងខាងអ័ក្សផ្លូវចំពោះទីក្រុង ទីរួមខេត្តនិងទីប្រជុំជន

-ផ្លូវរថភ្លើងចម្ងាយ ៣០ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកស្ថិតនៅក្រៅក្រុង

-ផ្លូវរថភ្លើងចម្ងាយ ១០០ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកក្នុងតំបន់ព្រៃភ្នំដែលមានថ្មរមៀលធ្លាក់ ឬតំបន់ព្រៃខ្ពស់ ។

ចំពោះអចលនវត្ថុដទៃទៀតដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ និងសម្បត្តិឯកជនរបស់រដ្ឋនឹងមានការកំណត់ដោយឡែក ។

៩_ក្រសួងមហាផ្ទៃ សហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ពេលវេលាជាក់ស្តែងអោយបានសមស្រប ដើម្បីអោយអាជ្ញាធរខេត្ត-ក្រុងអនុវត្តការរុះរើសំណង់អនាធិបតេយ្យអោយចេញផុតពីដីចំណីផ្លូវ និងផ្លូវរថភ្លើង ។ ចំពោះផ្លូវលំត្រូវមានការចូលរួមពីក្រសួងអភិវឌ្ឍន៍ជនបទ ។

១០_ចំពោះមុខ និងជាបន្ទាន់ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ចាប់ផ្តើមអនុវត្តការងាររបស់ខ្លួននៅតាមបណ្តោយផ្លូវជាតិលេខ ១ លេខ ៤ និងតាមបណ្តោយផ្លូវដែក ទៅរាជធានីភ្នំពេញ ហើយនិងឈានទៅអនុវត្តនៅទីកន្លែងដទៃទៀត តាមលំដាប់អាទិភាព ។

១១_គណៈកម្មការដោះស្រាយបាតុភាពដីធ្លីនៅតាមខេត្ត-ក្រុងទូទាំងប្រទេស ត្រូវតាមដានការអនុវត្តន៍របស់អាជ្ញាធរដែនដីខេត្ត-ក្រុង ដោយត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារ ដែលអនុវត្តបាន ព្រមទាំងការលំបាកស្មុគស្មាញក្នុងការអនុវត្តន៍ ដើម្បីរាជរដ្ឋាភិបាលមានវិធានការជាក់ស្តែង ។

✳ ទទួលបានសេចក្តីប្រកាសនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយអោយបានទូលំទូលាយ និងខិតខំអនុវត្តវិធានការខាងលើអោយមានប្រសិទ្ធភាពខ្ពស់ ។/.

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត_ក្រុង
- ឯកសារ_កាលប្បវត្តិ

# សេចក្ដីប្រកាស

# ស្ដីពី

# វិធានការគ្រប់គ្រង និង លុបបំបាត់ ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

*******

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ: ០១ ប្រក.

# សេចក្តីប្រកាស
## ស្តីពី
## វិធានការគ្រប់គ្រង និង លុបបំបាត់
## ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

******

ដោយពិនិត្យឃើញថា ទោះបីជាក្រឹត្យ- ច្បាប់ លេខ ៣៥ ក្រច. ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពី ការគ្រប់គ្រងវិស័យព្រៃឈើ , ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលនៅជាធរមាន និង លិខិតបទដ្ឋានជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់តាមដំណាក់កាលនីមួយៗ សំដៅមានវិធានការទប់ស្កាត់បទល្មើសលើវិស័យព្រៃឈើក៏ដោយ ក៏នៅតែមានជនខិលខូច បាននិងកំពុងឆ្លៀតឱកាសបំផ្លិចបំផ្លាញធនធានព្រៃឈើនៅឡើយ ។ ជាក់ស្តែងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាល បានសង្កេតឃើញថា ភាពអនាធិបតេយ្យលើវិស័យព្រៃឈើ កំពុងតែគំរាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុតគួរអោយព្រួយបារម្ភ ហើយបើសិនជាគំរិតនៃការបំផ្លិចបំផ្លាញដូចបច្ចុប្បន្ននេះនៅតែបន្តទៅទៀតនោះ ប្រទេសកម្ពុជានឹងបាត់បង់ធនធានព្រៃឈើដ៏មានតម្លៃស្តុកស្តម្ភនេះ ក្នុងកំឡុងពេលដ៏ខ្លីខាងមុខ ។ ការបាត់បង់ព្រៃឈើនេះ នឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើតុល្យភាព ប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងសេដ្ឋកិច្ច របស់កម្ពុជានៅពេលអនាគត ដែលកន្លងមកធនធានព្រៃឈើ ធ្លាប់តែស្រូបទាញយកនូវបរិមាណភ្លៀងដ៏ច្រើន ការពារដី និងរក្សាស្រទាប់ទឹកក្រោមដី កាត់បន្ថយបាននូវគ្រោះកាចនៃទឹកជំនន់ និង ភាពរាំងស្ងួត ។ ម្យ៉ាងទៀតបើគ្មានព្រៃឈើទេ វានឹងបណ្តាលអោយមានការហូរច្រោះនាំដីល្បាប់ ហូរចាក់ទៅក្នុងបឹងទន្លេសាប ធ្វើអោយខូចនូវមជ្ឈដ្ឋានសំរាប់ត្រីពង និង ជះឥទ្ធិពលអាក្រក់ទៅលើផលិតផលស្រូវនៅក្នុងតំបន់វាលទំនាបផងដែរ ។ ទន្ទឹមនឹងនេះ សត្វព្រៃក៏កំពុងតែទទួលរងនូវការបំផ្លិចបំផ្លាញដែលបង្កឡើងដោយជនគ្មានវិចារណញ្ញាណ ធ្វើអោយសត្វព្រៃមួយចំនួនបានរលត់ផុតពូជពីកម្ពុជា និងមួយចំនួនទៀតក៏កំពុងតែឈានទៅរកក្តីវិនាសទាំងស្រុង ។ រីឯការរំលោភបំពានរុករានទន្ទ្រានកាន់កាប់ដីព្រៃ ដីក្នុងតំបន់ការពារធម្មជាតិ ក្រោមរូបភាពតំបន់អភិវឌ្ឍន៍យោធិន និងអភិវឌ្ឍន៍កសិកម្ម និងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ក៏ជាបញ្ហាមួយដែលត្រូវដោះស្រាយជាបន្ទាន់ និងអោយមានប្រសិទ្ធិភាពបំផុត ។ រាជរដ្ឋាភិបាលបានប្រឹងប្រែងលើកវិធានការទប់ស្កាត់បទល្មើសព្រៃឈើ ដោយបានដាក់ចេញបទបញ្ជាជាច្រើនលើក ប៉ុន្តែការអនុវត្តពុំទាន់មាន

ប្រសិទ្ធិភាពពេញលេញ និងខ្ជាប់ខ្ជួន ។ ដោយរង់ចាំការអនុម័តច្បាប់ថ្មី ស្តីពីការថែរក្សា និង គ្រប់គ្រងព្រៃឈើ ក្នុងរយៈពេលដ៏ខ្លីខាងមុខ រាជរដ្ឋាភិបាលផ្តើមចេញពីសុន្ទរកថា នាថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៨ និង សេចក្តីប្រកាសកម្មវិធីនយោបាយ នាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ចាំបាច់ដាក់ចេញនូវវិធានការដូចតទៅ ÷

១- បញ្ឈប់ជាបន្ទាន់ និងជាកំហិតការធ្វើអាជីវកម្ម ការប្រមូលទិញ- លក់ និងដឹកជញ្ជូនឈើអនាធិបតេយ្យគ្រប់រូបភាព និង គ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស លើកលែងតែការធ្វើអាជីវកម្មស្របច្បាប់ក្នុងដែនព្រៃគុបសម្បទានមានច្បាប់អនុញ្ញាត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងបច្ចេកទេសយ៉ាងតឹងរ៉ឹងបំផុតពីសមត្ថកិច្ច រុក្ខា- ប្រមាញ់ ។ ដោយឡែកតម្រូវការឈើប្រើប្រាស់ក្នុងប្រទេស ត្រូវទិញយកពីការធ្វើអាជីវកម្មស្របច្បាប់របស់ ព្រៃសម្បទានក្នុងអត្រាពី ១០ % - ២០ % នៃផែនការអាជីវកម្មប្រចាំឆ្នាំតាមរយៈ នាយកដ្ឋានរុក្ខា- ប្រមាញ់ ក្នុងតម្លៃសមស្រប ។

២- ការងារគ្រប់គ្រង និងត្រួតពិនិត្យផល- អនុផលព្រៃឈើ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរុក្ខា- ប្រមាញ់គ្រប់ជាន់ថ្នាក់ ។ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ស្ថាប័នជំនាញផ្សេងៗ និងជនមានអំណាច ត្រូវបញ្ឈប់ជាបន្ទាន់នូវការជ្រៀតជ្រែក រំលោភបំពានចូលការងារព្រៃឈើ ។

៣- បញ្ចប់នូវការអនុញ្ញាតដឹកជញ្ជូនដោយរួចថ្លៃឈើឈរគ្រប់ប្រភេទ ។

៤- បញ្ឈប់ជាដាច់ខាតការចេញគោលការណ៍ថ្មីដែលអនុញ្ញាតអោយប្រមូលទិញឈើអនាធិបតេយ្យ ។រាល់គោលការណ៍ដែលបានអនុញ្ញាតអោយប្រមូលទិញ និងដឹកជញ្ជូនឈើអនាធិបតេយ្យគ្រប់ប្រភេទ ទោះពុំទាន់បានអនុវត្ត ឬ អនុវត្តពុំទាន់ចប់ក្តី ត្រូវទុកជាមោឃៈ ។ ឈើអនាធិបតេយ្យគ្រប់ប្រភេទចេញ ពីព្រៃសម្បទាន ណាក៏ដោយ ត្រូវធ្វើការចងក្រងសំណុំរឿងតាមនីតិវិធី ។

៥- ដើម្បីរក្សានិរន្តភាពព្រៃឈើ ដែលជាធនធានធម្មជាតិដ៏កម្រ និងសំដៅរក្សាបរិស្ថានធម្មជាតិផងនោះ ត្រូវបញ្ឈប់ការផ្តល់ព្រៃសម្បទានថ្មីបន្ថែមទៀត ។ ការបង្វែរដីព្រៃឈើរេចរឹល ទៅជាដីអភិវឌ្ឍន៍ដំណាំកសិកម្ម និងឧស្សាហកម្ម ត្រូវមានការសំរេចពីរាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋាន រុក្ខា- ប្រមាញ់)ត្រូវធ្វើការកំណត់ដែនព្រៃឈើបំរុងទុកជាបន្ទាន់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

៦- ត្រូវធ្វើការត្រួតពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងព្រៃសម្បទានទាំងអស់ ហើយលុបចោលកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនបានអនុវត្ត ឬ អនុវត្តមិនបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង តាមលំដាប់លំដោយអោយស្របតាមនីតិវិធី ។ ព្រៃសម្បទានដែលត្រូវបានដកហូត ត្រូវរក្សាទុកជាតំបន់ព្រៃការពារធម្មជាតិ និងព្រៃរៀបចំដោយពួក នឹងមិនត្រូវបានផ្តល់អោយក្រុមហ៊ុនណាផ្សេងទៀតឡើយ ។

៧- ចំពោះព្រៃសម្បទានដែលអនុវត្តតាមកិច្ចព្រមព្រៀង ត្រូវជំរុញអោយបំពាក់បន្ថែមមធ្យោបាយកែច្នៃអោយដល់កំរិតតាមកិច្ចព្រមព្រៀង ដើម្បីបង្កើនតម្លៃបន្ថែម និងបង្កើនការងារអោយពលរដ្ឋ ព្រមទាំងជំរុញអោយក្រុមហ៊ុនប្រតិបត្តិតាមដោយម៉ឺងម៉ាត់នូវការកាប់ឈើតាមគំរោងផែនការ និងបទដ្ឋានបច្ចេកទេស ជាពិសេសការដាំដើមឈើឡើងវិញក្នុងតំបន់ដែលបានកាប់ឈើ និងតំបន់ព្រៃរេចរឹល ។ ទន្ទឹមនឹងនេះ គ្រប់ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ ត្រូវទទួលខុសត្រូវលើរាល់សកម្មភាពអនាធិបតេយ្យព្រៃឈើ ដែលកើតមានឡើងនៅក្នុងតំបន់

ព្រៃរបស់ខ្លួន ដោយសហការជាមួយអាជ្ញាធរដែនដី ហើយចំពោះមុខម្ចាស់ព្រៃសម្បទាននីមួយៗ ត្រូវធ្វើព្រំប្រទល់ដែនព្រៃសម្បទានរបស់ខ្លួនអោយបានច្បាស់លាស់ជាចាំបាច់ ។

✓៨- បន្តហាមឃាត់ដាច់ខាតការនាំចេញឈើហ៊ុបមូល និងឈើអារសុទ្ធសាធ ។ រីឯផលិតផលឈើកែច្នៃដែលបានអនុញ្ញាតអោយនាំចេញ ត្រូវតែមានប្រភពឈើហ៊ុបមូលច្បាស់លាស់ចេញពីព្រៃគុបប្រចាំឆ្នាំ នៃព្រៃសម្បទាន ។

✓៩- បង្ក្រាបអោយបានដាច់ខាតរាល់ការចាប់ ការបរបាញ់ និងការដឹកជញ្ជូន ការនាំចេញសត្វព្រៃគ្រប់ប្រភេទ ។ រាល់មូលដ្ឋានទិញ - លក់ សត្វព្រៃគ្រប់ប្រភេទត្រូវបំបាត់ចោល ។

១០- បញ្ឈប់ជាបន្ទាន់នូវការកាប់ឆ្ការរានដីព្រៃធម្មជាតិ ឬ ចំការព្រៃដាំធ្វើជាកម្មសិទ្ធិ ។ រាល់ការចេញប័ណ្ណសំគាល់សិទ្ធិដែលពាក់ព័ន្ធនឹងដីព្រៃឈើ ត្រូវហាមឃាត់ជាដាច់ខាត រហូតដល់ការកំណត់ដែនព្រៃឈើជាផ្លូវការត្រូវបានសំរេច ។

១១- ជំរុញការដាំឈើនៅតំបន់ដីព្រៃរេចរឹលគ្រប់ខេត្ត- ក្រុង ទន្ទឹមនេះត្រូវរៀបចំសហគមន៍ព្រៃឈើ ដើម្បីដាំឈើ និងថែរក្សាព្រៃឈើអោយបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីផ្តល់ឈើថាមពល (អុស- ធ្យូង) ដល់ប្រជាពលរដ្ឋប្រើប្រាស់ ហើយត្រូវលើកទឹកចិត្តដល់ការមិនប្រើប្រាស់ថាមពលអុស- ធ្យូង ដោយខិតខំធ្វើការបង្វែរទិសពីតម្រូវការប្រើប្រាស់ថាមពលអុស- ធ្យូង ទៅជាការប្រើប្រាស់ថាមពលផ្សេងៗជំនួសវិញ ។ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ថវិកាជាតិសំរាប់ដាំឈើអោយបានទៀងទាត់ តាមផែនការ ប្រចាំឆ្នាំ ។

១២- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់- កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវបង្កលក្ខណៈងាយស្រួលអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ «នាយកដ្ឋាន រុក្ខា- ប្រមាញ់ »ធ្វើសកម្មភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ អោយមានប្រសិទ្ធិភាព ដូចជាៈរោងចក្រអារឈើ កែច្នៃឈើ មធ្យោបាយ សំភារៈឧបករណ៍ ដែលបំរើអោយសកម្មភាពអនាធិបតេយ្យ ។ ក្នុងករណីមានការស្នើសុំអន្តរាគមន៍ពីអង្គភាពជំនាញ កងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដី ត្រូវចូលរួមសហការដោយស្មោះត្រង់ និង មានប្រសិទ្ធិភាពខ្ពស់បំផុតក្នុងការបង្ក្រាបនេះ ហើយអាចប្រើប្រាសវិធានការគ្រប់បែបយ៉ាង រួមទាំងវិធានការសឹកផងដែរ ។

១៣- ត្រូវបញ្ឈប់ជាបន្ទាន់ការទាមទារយកប្រាក់កំរៃផ្សេងៗក្រៅផ្លូវការពីម្ចាស់ព្រៃគុបសម្បទានស្របច្បាប់ជាដាច់ខាត ។

១៤- បុគ្គល ឬ អង្គភាពណា ដែលបានបង្កអោយមានសកម្មភាពអនាធិបតេយ្យព្រៃឈើដោយផ្ទាល់ក្តី ដោយប្រយោលក្តី ឬ ការពារលួចលាក់ទុច្ចរិត ឬនាំចេញឈើ និងសត្វព្រៃខុសច្បាប់ ត្រូវទទួលវិន័យ ឬ ដកហូតមុខតំណែងតាមកំរិតដែលបានប្រព្រឹត្ត និងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។ បន្តផ្តល់កំរៃដល់មន្ត្រីរាជការដែលមានស្នាដៃក្នុងការងារបង្ក្រាបបទល្មើសព្រៃឈើ និងផលផល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៥- ដើម្បីមានមូលដ្ឋានខាងផ្លូវច្បាប់ក្នុងការថែរក្សា និង គ្រប់គ្រងវិស័យព្រៃឈើ អោយមានប្រសិទ្ធិភា[illegible] ខ្ពស់តាមវិធានការដូចខាងលើ រាជរដ្ឋាភិបាល ខិតខំរៀបចំព្រាងច្បាប់ ស្តីពីការថែរក្សា និង គ្រប់គ្រងព្រៃឈើ ឡើងវិញជាបន្ទាន់បំផុត អោយសមស្របតាមពេលវេលា និង សភាពការណ៍ជាក់ស្តែងក្នុងវិស័យព្រៃឈើ ហើ[illegible] ស្របទៅនឹងច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរដ្ឋសភាអនុម័តក្នុងពេលដ៏ឆាប់ខាងមុខនេះ ។ ទន្ទឹមនេះក្រសួងកសិក[illegible] រុក្ខាប្រមាញ់ និង នេសាទ ត្រូវព្រាងបទដ្ឋានអនុវត្តបច្ចេកទេសព្រៃឈើ ដើម្បីដាក់អោយក្រុមហ៊ុនព្រៃសម្បទាន អនុវត្តនៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ។

១៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការងារអនុវត្តបាន និងការលំបាកក្នុងការអនុវត្ត ដើម្បីរាជរដ្ឋាភិបាលមានវិធានការជាក់ស្តែង ។

១៧- ក្រសួង បរិស្ថាន ត្រូវសំរេចចាត់តាំងយន្តការសំរាប់តាមដានលើការអនុវត្តសេចក្តីប្រកាសនេះ តាមការចាំបាច់ ។

ទទួលបានសេចក្តីប្រកាសនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំអនុវត្តនូវវិធានការខាងលើដោយស្មារតីទទួលខុសត្រូវខ្ពស់ អោយមានប្រសិទ្ធិភាពខ្ពស់បំផុត ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ
- អគ្គនាយក នគរបាលជាតិ
- គ្រប់សាលាខេត្ត- ក្រុង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ

# សេចក្ដីសំរេច

# ស្ដីពី

# ការបង្កើតគណៈកម្មការជាតិពិភាក្សាផ្ដល់ យោបល់  និងដោះស្រាយបាតុភាពលើ ការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩ អនក្រ

ក្រសួងបរិស្ថាន
នាយកដ្ឋានការពារអភិរក្សធម្មជាតិ
ចូល លេខ...៥១៤៦... ធ.បស្ថ
ថ្ងៃទី..០១..ខែ..០៤..ឆ្នាំ២០០០

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិពិភាក្សាផ្តល់យោបល់ និង ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និង ការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការជាតិអន្តរក្រសួងមួយ ដើម្បីពិភាក្សាផ្តល់យោបល់ និង ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចតទៅ ៖

១_ ឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធាន

២_ ឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៣_ ឯកឧត្តម **ចំរុង តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៤_ ឯកឧត្តម **លី ធុជ** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៥_ ឧ.ឧ.ឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** អគ្គមេបញ្ជាការរងនៃបញ្ជាការដ្ឋានកងយោធពល ខេមរភូមិន្ទ សមាជិក

៦_ ឧ.ឧ.ឧត្តមសេនីយ៍ឯក **ហុក ឡង់ឌី** អគ្គនាយកនគរបាលជាតិ សមាជិក

៧_ ឧ.ឧ.ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៨_ ឯកឧត្តម **ស៊ិន សារុន** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩_ ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវណ្ណារឫទ្ធិ** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១០_ ឯកឧត្តម **អ៊ុំ ម៉ុនធឿន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១១_ ឯកឧត្តម **កែវ ខេមរា** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

១២_ ឯកឧត្តម អភិបាលខេត្ត_ក្រុង ដែលពាក់ព័ន្ធ សមាជិក

**ប្រការ ២** : គណៈកម្មការជាតិអន្តរក្រសួងនេះ មានភារកិច្ច និងបេសកកម្មដូចតទៅ ៖

- ចូលរួមពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ចូលរួមពិភាក្សាផ្តល់យោបល់ លើការងារអភិរក្ស និង អភិវឌ្ឍន៍តំបន់ការពារធម្មជាតិ
- លើកវិធានការទប់ស្កាត់ និង ដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតឡើងក្នុងតំបន់ការពារធម្មជាតិ
- ចូលរួមវាយតម្លៃ និង ពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ

**ប្រការ ៣** : គណៈកម្មការជាតិអន្តរក្រសួងនេះ ត្រូវបង្កើតអនុគណៈកម្មការចំរុះមួយនៅតាមបណ្តាខេត្ត_ក្រុង ពាក់ព័ន្ធដែលមានអភិបាលខេត្តរង ០១ រូប ជាប្រធាន ដើម្បីជាជំនួយការងារបំពេញភារកិច្ចនៅតាមបណ្តាខេត្ត_ក្រុង ដែលមានតំបន់ការពារធម្មជាតិ ។

**ប្រការ ៤** : គណៈកម្មការជាតិអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីស្តីការក្រសួងបរិស្ថាន និង ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**ប្រការ ៥** : សមាជិកគណៈកម្មការជាតិតំណាងអោយក្រសួង_ស្ថាប័ន ខេត្ត_ក្រុងនានា និងអនុគណៈកម្មការ ខេត្ត_ក្រុងត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ ២ ខាងលើនិងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការជាតិអន្តរក្រសួង ហើយរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត_ក្រុង អនុគណៈកម្មការ និង សមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០០*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ_កាលប្បវត្តិ*

# សេចក្ដីណែនាំ ស្ដីពី

## ការជំរុញអនុវត្ត អនុក្រឹត្យលេខ ៣៦អនក្រ.បក
## ស្ដីពី

# ការគ្រប់គ្រងសំណល់រឹង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ:......៤០......ប.ស្ថ.ស.ស១


រាជធានីភ្នំពេញ. ថ្ងៃទី..២០.. ខែ.កញ្ញា. ឆ្នាំ ១៩៩៩.

# សេចក្តីណែនាំ ស្តីពី
# ការជំរុញអនុវត្ត អនុក្រឹត្យលេខ ៣៦អនក្រ.បក
# ស្តីពី ការគ្រប់គ្រងសំណល់រឹង

កន្លងមកការគ្រប់គ្រងសំណល់រឹង (សំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់) ពុំមានភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស បង្កឱ្យមានផលប៉ះពាល់ទៅដល់គុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។ ដើម្បីកែលំអបញ្ហានេះ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យលេខ៣៦ 'អនក្រ ស្តីពី ការគ្រប់គ្រងសំណល់រឹង នាថ្ងៃទី ២៧ មេសា ១៩៩៩ ។

ដូចនេះ ដើម្បីជំរុញកិច្ចអនុវត្តអនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹងនៅតាមខេត្ត ក្រុង អោយមានប្រសិទ្ធិភាព ក្រសួងបរិស្ថានសូមធ្វើការណែនាំមន្ទីរបរិស្ថានខេត្ត ក្រុងអនុវត្តជាក់ស្តែង ដូចខាងក្រោម :

១-គោលដៅ និងវិសាលភាពអនុវត្តអនុក្រឹត្យ

-ពង្រឹងការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេស ដែលធានាសុវត្ថិភាពដល់បរិស្ថាន និងសុខភាពសាធារណៈ ។

-ត្រូវអនុវត្តលើសកម្មភាពបោះចោល ទុកដាក់ ប្រមូលស្តុក ដឹកជញ្ជូន កែច្នៃនិងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

២-និតិវិធីក្នុងការចូលរួមគ្រប់គ្រងសំរាម

-ត្រូវចូលរួមផ្តល់យោបល់បច្ចេកទេស ជូនដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តទំការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណនិងការចាក់ចោលសំរាម ក្នុងគោលដៅទប់ស្កាត់ការ

បំពុលបរិស្ថាន ថែរក្សាសោភ័ណ្ឌភាពខេត្ត-ក្រុង និងសុខភាពសាធារណៈ ដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

-ត្រូវពិនិត្យលើការអនុវត្តន៍របស់អង្គភាព ឬភ្នាក់ងារប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃកាត់បន្ថយបរិមាណនិងការចាក់ចោល និងត្រូវរាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងក្រសួងបរិស្ថាន ប្រសិនបើពិនិត្យឃើញសកម្មភាពអនុវត្តពុំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបង្កការប៉ះពាល់ដល់បរិស្ថាន ។

-ត្រូវស្រង់ទិន្នន័យបរិមាណសំរាមជាប្រចាំដែលពាក់ព័ន្ធ ការដឹកជញ្ជូនយកទៅចាក់ចោល ការដុតសំរាម សំរាមមិនត្រូវបានគេប្រមូល សំរាមយកទៅកែច្នៃ ឬប្រើប្រាស់ឡើងវិញ ហើយត្រូវផ្ញើសំរង់ទិន្នន័យប្រចាំឆ្នាំមកក្រសួង ។

-ត្រូវសុំយោបល់ពីក្រសួង ក្នុងករណីមានគំរោងបង្កើតទីតាំងចាក់ ឬដុត សំរាម ឬមានការវិនិយោគនាំសំរាមចេញ ។

៣-និតិវិធីចូលរួមគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

-ត្រូវចុះស្រង់ទិន្នន័យសំណល់រឹង (សំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់) នៅតាមបណ្តាប្រភពបំពុល ដូចមានចែងក្នុងប្រការ ២ នៃប្រកាសលេខ ១២ បស្ថ-ប្រក ចុះថ្ងៃទី ០២ មិថុនា ១៩៩៩ ។

-ត្រូវធ្វើការណែនាំម្ចាស់សំណល់រឹង អោយធ្វើការទុកដាក់ ស្តុកនិងកាត់បន្ថយបរិមាណ ដោយផ្អែកលើគោលការណ៍ណែនាំគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

-ត្រូវចូលរួមផ្តល់យោបល់លក្ខណៈបច្ចេកទេស ជូនអាជ្ញាធរមូលដ្ឋាន លើការងារប្រមូល ដឹកជញ្ជូន ស្តុក ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលចេញពីប្រភព ដូចមានក្នុងមាត្រា ១៦ នៃអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

-ត្រូវពិនិត្យ និងធ្វើរបាយការណ៍មកក្រសួងពីការអនុវត្តន៍របស់អង្គភាព ឬភ្នាក់ងារប្រមូល ដឹកជញ្ជូន ស្តុក និងចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលចេញពីប្រភព ដូចមានចែងក្នុងមាត្រា ១៦ នៃអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

-ត្រូវសុំយោបល់ពីក្រសួង លើការងារគំរោងវិនិយោគសាងសង់ទីកន្លែង ចាក់ ស្តុក ឬដុត ឬការនាំសំណល់ប្រកបដោយគ្រោះថ្នាក់ចេញទៅប្រទេសក្រៅ ។

៤-និតិវិធីនៃការធ្វើអធិការកិច្ច

-ត្រូវចុះធ្វើអធិការកិច្ចដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នៅពេលមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានការលួចចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ។

-ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ នៅពេលទទួលដំណឹង ឬជួបប្រទះនឹងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ បង្កឡើងដោយការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ហើយត្រូវរាយការណ៍មកក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

៥-និតិវិធីនៃការអនុវត្តន៍វិធានការចំពោះបទល្មើសការចាក់ចោលសំណល់រឹង

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តវិធានការចំពោះអ្នកប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង ទៅតាមវង្វង់សមត្ថកិច្ចរបស់ខ្លួន ដែលបានបែងចែកដោយប្រកាសរបស់ក្រសួងលេខ ១២ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៩៩ ។ វិធានការដែលត្រូវអនុវត្ត គឺអាស្រ័យទៅតាមទំហំ និងប្រភេទនៃបទល្មើសរួមមាន :

១-ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ តំរូវអោយកែប្រែសកម្មភាពល្មើស

២-ការផ្អាកសកម្មភាពជាបណ្តោះអាសន្ន

៣-ការពិន័យអន្តរការណ៍

៤-ការធ្វើបណ្តឹងទៅតុលាការ

ក-ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ

ការចេញបញ្ជាជាលាយលក្ខណ៍អក្សរចំពោះប្រភពបំពុលមានលក្ខណៈពីរយ៉ាងគឺ:

- ព្រមាន និងតំរូវអោយបញ្ឈប់បទល្មើស ឬ កែប្រែកំហុសឆ្គងណាមួយ ដែលប៉ះពាល់ដល់បរិស្ថាន ។
- លុបបំបាត់ការបំពុល ។

ការចេញបញ្ជាជាលាយលក្ខណ៍អក្សរចំពោះប្រភពបំពុល គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។ ក៏ប៉ុន្តែនៅតាមមូលដ្ឋានខេត្ត -ក្រុង ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ អាចធ្វើដោយអភិបាល ខេត្ត ក្រុងតាមសំណើរបស់មន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះប្រភពបំពុលដែលស្ថិតក្នុងក្របខ័ណ្ឌវង្វង់សមត្ថកិច្ចត្រួតពិនិត្យរបស់មន្ទីរបរិស្ថានខេត្ត-ក្រុង ។

ខ-ការផ្អាកសកម្មភាពជាបណ្តោះអាសន្ន

ការផ្អាកសកម្មភាពរបស់ប្រភពបំពុលជាបណ្តោះអាសន្ន ត្រូវអនុវត្តចំពោះករណីដែលធ្ងន់ធ្ងរ និងយោងទៅតាមតំរូវការចាំបាច់ នៃផលប្រយោជន៍សាធារណៈ ក្នុងករណីដែលមានភស្តុតាងជាក់ច្បាស់លាស់នៃបទល្មើស ព្រមទាំងមានការពិគ្រោះយោបល់ជាមួយនាយកដ្ឋានដែនការ និង កិច្ចការច្បាប់របស់ក្រសួងបរិស្ថាន និង ក្រសួងសាមី ដែលប្រភពបំពុលនោះស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រង ។ បញ្ជាជា លាយលក្ខណ៍អក្សរតំរូវអោយប្រភពបំពុលផ្អាកសកម្មភាពជាបណ្តោះអាសន្ន ត្រូវចេញដោយក្រសួងបរិស្ថាន ។

គ-ការពិន័យអន្តរការណ៍

ការពិន័យអន្តរការណ៍ចំពោះបទល្មើស និងអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងការបំពុលទឹក ជាសមត្ថកិច្ចរបស់មន្ទីរបរិស្ថានខេត្ត-ក្រុង និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ។ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ឬមន្ទីរបរិស្ថានខេត្ត-ក្រុង អនុវត្តការពិន័យនេះក្នុងករណីដែលមានភស្តុតាងជាក់ច្បាស់លាស់នៃបទល្មើស ។ ចំនួនទឹកប្រាក់នៃការពិន័យអន្តរការណ៍ ត្រូវអនុវត្តទៅតាម មាត្រា ទី ២១ ជំពូក ៩ នៃច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មានសិទ្ធិសំរេចពិន័យ ពី ៥សែនរៀល ដល់ ១០លាន រៀល ។ មន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធិសំរេចពិន័យពី ៥សែនរៀល ដល់ ២លាន រៀល ដោយថ្លឹងថ្លែងទៅតាមកំរិត និងលក្ខណៈនៃបទល្មើស ។ នាយកដ្ឋានផែនការ និងកិច្ចការច្បាប់នៃក្រសួងបរិស្ថានត្រូវជួយអោបយោបល់លើទិដ្ឋភាពច្បាប់ ចំពោះការអនុវត្តន៏ការផាកពិន័យអន្តរការណ៍ និងបច្ចេកទេសស្រាវជ្រាវរកភស្តុតាងនៃបទល្មើស ។ នាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ចរបស់

ក្រសួងត្រូវរៀបចំវិក័យប័ត្រសំរាប់ធ្វើការផាកពិន័យ ។ ថវិកាដែលបានមកពីការផាកពិន័យត្រូវបង់ចូលថវិការដ្ឋ ។

ឃ-ការធ្វើបណ្តឹងទៅតុលាការ

ចំពោះបទល្មើសដែលផុតពីកំរិតពិន័យអន្តរការណ៍នោះ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដោយសហការជាមួយនាយកដ្ឋានផែនការ និងកិច្ចការច្បាប់របស់ក្រសួង ត្រូវធ្វើជាសេនាធិការអោយក្រសួងក្នុងការរៀបចំសំណុំរឿងប្តឹងទៅតុលាការ ។ ចំពោះបទល្មើសដែលប្រព្រឹត្តដោយប្រភពបំពុល ដែលស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់មន្ទីរបរិស្ថានខេត្ត - ក្រុងនោះ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវធ្វើជាសេនាធិការអោយក្រសួងបរិស្ថាន និងអាជ្ញាធរដែនដីរបស់ខ្លួនក្នុងការរៀបចំសំណុំរឿងប្តឹងទៅតុលាការ ។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកដ្ឋាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

**ចំលងជូន**

- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ ស្តីពី

## ការជំរុញអនុវត្ត អនុក្រឹត្យលេខ ២៧ អនក្រ.បក
## ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ:...៥១.....ប.ស្ត.ស.ស.វ

រាជធានីភ្នំពេញ. ថ្ងៃទី...២០ ខែកញ្ញា ឆ្នាំ ១៩៩៩

## សេចក្តីណែនាំ ស្តីពី
## ការជំរុញអនុវត្តអនុក្រឹត្យលេខ ២៧ អនក្រ.បក
## ស្តីពី ការត្រួតពិនិត្យការបំពុលទឹក

យោងទៅលើសកម្មភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេស ពិសេសលើវិស័យឧស្សាហកម្ម -សិប្បកម្ម គមនាគមន៍ ទេសចរណ៍ ។ល។ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ លើការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ដែលបង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍ខាងលើ ដោយបានអនុម័តអនុក្រឹត្យលេខ ២៧ អនក្រ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក នៅថ្ងៃទី ៦ ខែ មេសា ១៩៩៩ ។

ដើម្បីជំរុញការអនុវត្តន៍អនុក្រឹត្យលេខ ២៧ អនក្រ.បក អោយមានប្រសិទ្ធិភាពនៅតាមបណ្តាមូលដ្ឋាន ខេត្ត-ក្រុង ក្រសួងបរិស្ថានសូមធ្វើការណែនាំមន្ទីរបរិស្ថានខេត្ត-ក្រុង អនុវត្តដូចខាងក្រោម:

### ១-គោលដៅ និងវិសាលភាពអនុវត្តនៃអនុក្រឹត្យ

ពង្រឹងការតាមដាន និងការពារគុណភាពទឹក តាមរយៈការដាក់បញ្ញត្តិ និងការត្រួតពិនិត្យប្រភពបំពុល ដែលបញ្ចេញសំណល់រាវចូលតំបន់ទឹកសាធារណៈ ឬលូសាធារណៈ ។

### ២-ការដាក់បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

-ត្រូវណែនាំ និងកំណត់ការបញ្ចេញសំណល់រាវ ពីប្រភពបំពុលដូចមានចែងក្នុងប្រការ ២ នៃប្រកាសលេខ ១២ បស្ត.ប្រក ចុះថ្ងៃទី ០២.៦.៩៩ ទៅតាមកំរិតស្តង់ដារ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។ ចំពោះការបញ្ចេញសំណល់រាវ ដែលលើសពីស្តង់ដារត្រូវចាត់ទុកជា អំពើល្មើសច្បាប់ ។

- ត្រូវចាត់វិធានការបំបាត់ការចាក់ចោលសំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬលូសាធារណៈ ។

- ត្រូវចាត់វិធានការតំរូវអោយម្ចាស់លំនៅស្ថាន និងអង្គភាពរដ្ឋបាលសាធារណៈ ដែលតាំងនៅក្នុងតំបន់គ្មានលូសាធារណៈ រៀបចំប្រព័ន្ធច្រោះសំអាតសំណល់រាវរបស់ខ្លួន ។

- ត្រូវអញ្ជើញម្ចាស់ប្រភពបំពុលដូចមានចែងក្នុងប្រការ ២ នៃប្រកាសលេខ ១២ បស្ថ.ប្រក ចុះថ្ងៃទី០២.៦.៩៩ មកដាក់ពាក្យសុំអនុញ្ញាតបញ្ចេញសំណល់រាវប្រសិនបើពិនិត្យឃើញថាវាឆ្លើយតបទៅនឹងតំរូវការដូចមានចែងក្នុងមាត្រា ១០ មាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។

៣-និតិវិធីនៃការចេញលិខិតអនុញ្ញាតបញ្ចេញ ឬដឹកសំណល់រាវ

- ការចេញលិខិតអនុញ្ញាតបញ្ចេញចោល ឬដឹកសំណល់រាវទៅទីដទៃ ត្រូវចេញដោយមន្ទីរបរិស្ថានខេត្ត -ក្រុង ប្រសិនបើសំណល់នោះ មិនត្រូវបានចាត់ចូលក្នុងប្រភេទសំណល់គ្រោះថ្នាក់ ។ ក្នុងករណីដែលសំណល់រាវនោះ ជាប្រភពសំណល់គ្រោះថ្នាក់ ត្រូវសុំយោបល់ ពីក្រសួងបរិស្ថាន ។ ការបញ្ចេញសំណល់រាវដោយគ្មានលិខិតអនុញ្ញាត ត្រូវចាត់ទុកជាអំពើល្មើស ។

-តំលៃលិខិតអនុញ្ញាតលើការបញ្ចេញសំណល់រាវមានរយៈពេលបីឆ្នាំ ។ ចំពោះលិខិតអនុញ្ញាតដឹកជញ្ជូនសំណល់រាវត្រូវកំណត់រយៈពេលសមស្របបំផុត ។

-ត្រូវសុំអនុញ្ញាតជាថ្មី ប្រសិនបើមានការកែប្រែប្រព័ន្ធបញ្ចេញសំណល់រាវ ។

៤-និតិវិធីនៃការត្រួតពិនិត្យប្រភពបំពុល

-ត្រូវមានលិខិតបញ្ជាបេសកកម្ម និងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការសំរាប់បង្ហាញក្នុងពេលចុះត្រួតពិនិត្យប្រភពបំពុល ។ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ឬ អាជ្ញាធរមូលដ្ឋាន ក្នុងករណីយល់ថាជាការចាំបាច់ ។

-ត្រូវមានកំណត់ហេតុ ឬកិច្ចសន្យារវាងមន្ត្រីជំនាញ និងមានការឯកភាពពីប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ជាមួយម្ចាស់ប្រភពបំពុល ដែលទទួលយល់ព្រមអនុវត្តតាមការណែនាំ អោយកាត់បន្ថយការបំពុលដោយកំណត់ពេល វេលាច្បាស់លាស់ ។

- ត្រូវរៀបចំទិន្នន័យ ដែលទាក់ទងនឹងសំណល់រាវ ដែលបង្កើតដោយប្រភពបំពុល និងលំនៅស្ថាន ឬ អាគាររដ្ឋបាលសាធារណៈ ហើយត្រូវផ្ញើបញ្ជីទិន្នន័យសរុបប្រចាំឆ្នាំមកក្រសួង ។

-ត្រូវត្រួតពិនិត្យប្រភពបំពុលក្នុងរយៈពេលយ៉ាងឆាប់ ៤៥ ថ្ងៃម្តង ។

-ត្រូវយកសំណាកសំណល់រាវពីប្រភពបំពុល មកធ្វើការវិភាគនៅមន្ទីរពិសោធន៍ក្រសួង ក្នុងករណីដែលមានការសង្ស័យថាវាបង្កអោយមាននូវការបំពុលទឹក ។

## ៥-និតិវិធីនៃការត្រួតពិនិត្យ គុណភាពទឹកតំបន់ទឹកសាធារណៈ

-ត្រូវធ្វើការអង្កេតនិងធ្វើរបាយការណ៍ ពីស្ថានភាពគុណភាពទឹក នៅតាមតំបន់ទឹកសាធារណៈ និងពីឥទ្ធិពលនៃមជ្ឈដ្ឋានជុំវិញ ដែលអាចបង្កអោយមានការបំពុលទឹក ។ ក្នុងករណីចាំបាច់ត្រូវដងយកសំណាកទឹកមកវិភាគនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

-ក្នុងករណីមានការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ចាំបាច់ត្រូវជូនដំណឹងជាបន្ទាន់មកក្រសួង ឬ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ហើយត្រូវផ្សព្វផ្សាយតាមគ្រប់រូបភាព ដល់ប្រជាពលរដ្ឋនៅតំបន់នោះ អោយមានការប្រុងប្រយ័ត្ន ។

-ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការទប់ស្កាត់ការបំពុលទឹក និង ស្តារគុណភាពទឹកនៅតំបន់ទឹកសាធារណៈនោះឡើងវិញ ។

## ៦-និតិវិធីនៃការធ្វើអធិការកិច្ច

-ត្រូវចុះធ្វើអធិការកិច្ចដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នៅពេលមានពាក្យបណ្តឹង ឬ សេចក្តីរាយការណ៍ ថាប្រភពបំពុលណាមួយបានឬកំពុងបង្កអោយការបំពុលទឹក ដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ ។

-ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ នៅពេលទទួលដំណឹង ឬជួបប្រទះ នឹងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរបង្កឡើងដោយការបំពុលទឹក ហើយត្រូវរាយការណ៍មកក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

-ក្នុងករណីបទល្មើសជាក់ស្តែងដែលនាំអោយមានការបំពុលទឹកត្រូវធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាង និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសមិនធ្ងន់ធ្ងរ តែប្រសិនបទល្មើសនោះបង្កអោយមានការប៉ះពាល់ធ្ងន់ធ្ងរ ត្រូវស្នើសុំកំលាំងមានសមត្ថកិច្ច ដែលនៅជិតកន្លែងកើតហេតុ មកចូលរួមដើម្បីធ្វើកំណត់ហេតុ ឃាត់ទុកភស្តុតាង ( រួមទាំងអ្នកប្រព្រឹត្តល្មើស ) ហើយរៀបចំសំណុំបែបបទបញ្ជូនទៅតុលាការ ។

## ៧-និតិវិធីនៃការអនុវត្តន៏វិធានការ ចំពោះបទល្មើសបំពុលទឹក

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តវិធានការចំពោះអ្នកប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃអនុក្រឹត្យស្តីពីការបំពុលទឹក ទៅតាមវង្វង់សមត្ថកិច្ចរបស់ខ្លួន ដែលបានបែងចែកដោយប្រកាសរបស់ក្រសួងលេខ ១២ ចុះថ្ងៃទី . ០២ ខែ. មិថុនា ឆ្នាំ ១៩៩៩ ។ វិធានការដែលត្រូវអនុវត្តគឺអាស្រ័យទៅ តាមទំហំ និងប្រភេទ នៃបទល្មើសមានដូចខាងក្រោម :

១-ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ តំរូវអោយកែប្រែសកម្មភាពល្មើស

២-ការផ្អាកសកម្មភាពជាបណ្តោះអាសន្ន

៣-ការពិន័យអន្តរការណ៍

៤-ការធ្វើបណ្តឹងទៅតុលាការ

ក-ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ

ការចេញបញ្ជាជាលាយលក្ខណ៍អក្សរចំពោះប្រភពបំពុលណាមួយធ្វើឡើងដោយក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានខេត្ត ក្រុង តាមការប្រគល់សិទ្ធិពីក្រសួងបរិស្ថាន ។ បញ្ជារជាលាយលក្ខអក្សរនេះមានលក្ខណៈពីរយ៉ាងគឺ

-ព្រមាន និងតំរូវអោយបញ្ឈប់បទល្មើស ឬ កែប្រែកំហុសឆ្គងណាមួយ ដែលប៉ះពាល់ដល់ការបំពុលទឹក ។

-លុបបំបាត់ការបំពុល ។

ចំពោះមូលដ្ឋានខេត្ត-ក្រុង ការចេញបញ្ជាជាលាយលក្ខណ៍អក្សរ អាចធ្វើដោយអភិបាលខេត្ត ឬ ក្រុង តាមសំណើរបស់មន្ទីរបរិស្ថាន ខេត្ត-ក្រុង ចំពោះប្រភពបំពុលដែលស្ថិតក្នុងក្របខ័ណ្ឌវង្វង់សមត្ថកិច្ចត្រួតពិនិត្យរបស់មន្ទីបរិស្ថានខេត្ត -ក្រុង ។

ខ-ការផ្អាកសកម្មភាពជាណេ្តាះអាសន្ន

ការផ្អាកសកម្មភាពរបស់ប្រភពបំពុលជាបណ្តោះអាសន្ន ត្រូវអនុវត្តចំពោះករណីដែលធ្ងន់ធ្ងរ និងយោងទៅតាមតំរូវការចាំបាច់ នៃផលប្រយោជន៍សាធារណៈ ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់នៃបទល្មើស ព្រមទាំងមានការពិគ្រោះយោបល់ជាមួយមន្ត្រីផ្នែកច្បាប់ របស់ក្រសួងបរិស្ថាន និងក្រសួងសាមុីដែលប្រភពបំពុលនោះស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រង ។ បញ្ជាជាលាយលក្ខណ៍អក្សរដែលតំរូវអោយប្រភពបំពុលផ្អាកសកម្មភាពបណ្តោះអាសន្ន ត្រូវចេញដោយក្រសួងបរិស្ថាន ។

គ-ការពិន័យអន្តរការណ៍

ការពិន័យអន្តរកាណ៍ចំពោះបទល្មើស នឹងអនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ជាសមត្ថកិច្ចរបស់មន្ទីរបរិស្ថានខេត្ត-ក្រុង និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ។ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ឬ មន្ទីរបរិស្ថានខេត្ត-ក្រុង អនុវត្តការពិន័យនេះ ក្នុងករណីមានភស្តុតាងពិតប្រាកដ

ច្បាស់លាស់នៃបទល្មើស ។ ចំនួនទឹកប្រាក់នៃការពិន័យអន្តរការណ៍ត្រូវអនុវត្តទៅតាមមាត្រាទី ២១ ជំពូក ៩ នៃច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មានសិទ្ធសំរេចពិន័យពី ៥សែនរៀល ដល់ ១០លានរៀល ឯមន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធសំរេចពិន័យពី ៥ សែន រៀល ដល់ ២លាន រៀលដោយថ្លឹងថ្លែងទៅតាមកំរិត និងលក្ខណៈនៃបទល្មើស ។ នាយកដ្ឋានផែនការ និងកិច្ចកាច្បាប់នៃក្រសួងបរិស្ថានត្រូវជួយ អោយយោបល់លើទិដ្ឋភាពច្បាប់ ចំពោះការអនុវត្តការផាកពិន័យអន្តរការណ៍ និងបច្ចេកទេសស្រាវជ្រាវ រកភស្តុតាងនៃបទល្មើស ។ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ចរបស់ក្រសួងបរិស្ថាន ត្រូវរៀបចំវិក័យប័ត្រសំរាប់ធ្វើការផាកពិន័យ ។ ថវិកាដែលបានមកពីការផាកពិន័យត្រូវបង់ចូលថវិការដ្ឋ ។

### ឃ-ការធ្វើបណ្តឹងទៅតុលាការ

ចំពោះបទល្មើស ដែលផុតពីកំរិតពិន័យអន្តរកាណ៍នោះ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដោយសហការជាមួយនាយកដ្ឋានផែនការ និង កិច្ចការច្បាប់របស់ក្រសួង ត្រូវធ្វើជាសេនាធិការអោយក្រសួងក្នុងការរៀបចំសំណុំ រឿងប្តឹងទៅតុលាការ ។ ចំពោះបទល្មើសដែលប្រព្រឹត្តដោយប្រភពបំពុលដែលស្ថិតក្នុងរង្វង់សមត្ថកិច្ច របស់មន្ទីរបរិស្ថានខេត្ត-ក្រុង នោះមន្ទីរបរិស្ថានខេត្ត-ក្រុងត្រូវធ្វើជាសេនាធិការ អោយក្រសួងបរិស្ថាន និង អាជ្ញាធរដែនដីរបស់ខ្លួនក្នុងការរៀបចំសំណុំរឿងប្តឹងទៅតុលាការ ។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកដ្ឋាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្ត អោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រដ្ឋមន្ត្រី

ម៉ុក ម៉ារ៉េត

ចំលងជូន

-គ្រប់សាលាខេត្ត -ក្រុង

-មន្ទីរបរិស្ថានខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

# សេចក្ដីណែនាំ

## ស្ដីពី

# ការគ្រប់គ្រង
# សំណល់គ្រោះថ្នាក់វេជ្ជសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

រាជធានីភ្នំពេញ ថ្ងៃទី 26 ខែ ឧសភា ឆ្នាំ 2000

87 សជណ

# សេចក្តីណែនាំ

## ស្តីពី ការគ្រប់គ្រងសំណល់គ្រោះថ្នាក់រោងចក្រ

__យោង:__ - ព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ។ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

- អនុក្រឹត្យលេខ ២៧ អនក្រ / បក ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។
- អនុក្រឹត្យលេខ ៣៦ អនក្រ /បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

ដោយពិនិត្យឃើញថា ការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅតាមរោងជាងជួសជុលគ្រឿងយន្ត ឬ រោងចក្រសហគ្រាសដែលមានលក្ខណៈមិនសមស្របទៅតាមបច្ចេកទេសដូចជា : សំណល់ប្រេងឥន្ធនៈ និងខ្លាញ់ សំណល់កកអាងស្តុក ឬ អាងប្រព្រឹត្តកម្ម និងសំណល់ចេញពីដំណើរការផលិតកម្ម ។ កន្លងមកនេះ មានការដឹកសំណល់គ្រោះថ្នាក់រោងចក្រយកទៅចាក់ចោលនៅតាមទីវាល និងតំបន់ទឹកសាធារណៈ ដែលជាហេតុបង្កអោយមានការបំពុលបរិស្ថាន និង ប៉ះពាល់ទៅ ដល់សុខភាពសាធារណៈ ។

ដើម្បីជំរុញការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅតាមរោងចក្រ សហគ្រាស និងរោងជាងជួសជុលគ្រឿងយន្ត អោយមានភាពល្អប្រសើរ សំដៅទប់ស្កាត់ការបំពុលបរិស្ថាន និង ការពារសុខ ភាពសាធារណៈ ក្រសួងបរិស្ថានសូមធ្វើការ ណែនាំដូចខាងក្រោម :

១. ត្រូវរៀបចំទុកដាក់សំណល់ប្រេងម៉ាស៊ីន និងសំណល់ប្រេងលាងក្នុងការជួសជុលគ្រឿងចក្រអោយបានសមស្រប និងជៀសវាងការបង្ហៀរ ឬចាក់ចូលទៅក្នុង បណ្តាញលូ ឬប្រភពទឹកសាធារណៈ ។

២ . ត្រូវធ្វើការហាល ឬគៀបសំងួតសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ដែលបញ្ចេញពីខ្សែសង្វាក់ផលិតកម្ម និងធ្វើការស្តុកទុកបណ្តោះអាសន្នអោយបានសមស្របនៅក្នុងទីតាំងរបស់ខ្លួន ជៀសវាងការប៉ះពាល់ដល់គុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

៣ . ហាមដាច់ខាតការចាក់ចោល ឬដឹកសំណល់ភក់លាយឡំជាមួយសំណល់រឹងលំនៅស្ថាន ។

៤. ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការដឹកជញ្ជូនសំណល់ភក់ស្ងួតចេញពីទីតាំងរោងចក្រ-សហគ្រាស ទៅកាន់ទីកន្លែងដ៏ទៃក្នុងគោលបំណងណាមួយ ។

៥. ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន សំរាប់ការបញ្ចេញសំណល់រាវរោងចក្រចូលទៅក្នុងលូ ឬតំបន់ទឹកសាធារណៈ ។

ទទួលបានសេចក្តីណែនាំនេះ ម្ចាស់រោងចក្រ រោងជាងជួសជុលគ្រឿងយន្តទាំងអស់ ត្រូវអនុវត្តការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដែលបង្កើតនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណីមិនអនុវត្តតាម ឬអនុវត្តផ្ទុយទៅនឹងសេចក្តីណែនាំខាងលើ ក្រសួងបរិស្ថាន និងចាត់វិធានការតាមផ្លូវច្បាប់ ។

រដ្ឋមន្ត្រី

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- សាលាខេត្ត-ក្រុង

" <u>ដើម្បីជូនជ្រាបជាព័ត៌មាន</u> "

- អគ្គនាយកដ្ឋាន
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

" <u>ដើម្បីមុខការ</u> "

- មន្ទីរបរិស្ថានខេត្ត-ក្រុង " <u>ដើម្បីសហការតាមដានការអនុវត្ត</u> "
- ឯកសារ កាលប្បវត្តិ

# សេចក្តីណែនាំ

## ស្តីពី

## ការគ្រប់គ្រងសំណល់រឹងតាមបណ្តា
## រោងចក្រ សហគ្រាស និងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ:..០១១..សរណន.ប.ស្ថ

រាជធានីភ្នំពេញ. ថ្ងៃទី..១៦..ខែមករា ឆ្នាំ២០០៣

# សេចក្តីណែនាំ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹងតាមបណ្តារោងចក្រ សហគ្រាស និងក្រុមហ៊ុន

ដោយពិនិត្យឃើញថា បច្ចុប្បន្ននេះ ការអនុវត្តន៍លើការទុកដាក់ ការប្រមូល និងការដឹកជញ្ជូនសំណល់រឹង-សំរាមប្រភេទសំណល់លំនៅស្ថាន និងសំណល់រឹងឧស្សាហកម្មនៅមានភាពលាយឡំគ្នា ពុំទាន់បានឆ្លើយតបតាមការកំណត់របស់ក្រសួងបរិស្ថាន ហើយក៏ធ្វើឱ្យមានការលំបាក និងភ័ន្តច្រឡំដល់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹង ។ ដូចនេះ ដើម្បីដោះស្រាយបាននូវរាល់បាតុភាពនិងធានាបានដល់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាព និងជំរុញអនុវត្តអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំណល់រឹង" និងប្រកាសលេខ ១៤៨ ប្រក.បស្ថ របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០០២ ស្តីពី " ការប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហកម្មក្នុងរាជធានីភ្នំពេញ " ក្រសួងបរិស្ថាន សូមធ្វើការណែនាំដល់ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ-សហគ្រាស និងក្រុមហ៊ុនទាំងអស់ត្រូវអនុវត្តតាម គោលការណ៍មួយចំនួនដូចខាងក្រោម :

១. រោងចក្រ- សហគ្រាសទាំងអស់ត្រូវធ្វើការបែងចែកសំណល់រឹងជាពីរប្រភេទដូចខាងក្រោម គឺ :

ក- សំណល់រឹង-សំរាម ជាប្រភេទដែលមានប្រភពចេញពីផ្ទះបាយ និងការិយាល័យរបស់រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ។

ខ- សំណល់រឹងឧស្សាហកម្ម ជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពចេញពីចង្វាក់ផលិតកម្មរបស់រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ( ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ ១៤៨ ប្រក.បស្ថ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០២ ) ។

២. ការទុកដាក់ និងស្តុកទុកបណ្តោះអាសន្ននូវសំណល់រឹងទាំងពីរប្រភេទខាងលើ ត្រូវដាក់នៅក្នុងរោង ឬ កន្លែងដែលធានាសុវត្ថិភាព និងដាច់ដោយឡែកពីគ្នា ព្រមទាំងមានការសរសេរបង្ហាញនូវប្រភេទសំណល់រឹង-សំរាម ឬ សំណល់រឹងឧស្សាហកម្មឱ្យបានច្បាស់លាស់ ដើម្បីឱ្យក្រុមហ៊ុនប្រមូល និងធ្វើការដឹកជញ្ជូនយកសំណល់ទាំងនោះទៅតាមប្រភេទសំណល់ដែលទទួលខុសត្រូវរៀងៗខ្លួន ។

៣. ការចុះកិច្ចសន្យាក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹងទាំងពីរប្រភេទខាងលើ អាចប្រព្រឹត្តទៅបានតែចំពោះក្រុមហ៊ុន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មស្របច្បាប់ដូចខាងក្រោម :

ក- ក្រុមហ៊ុន Cintri ( Cambodia ) Ltd. ទទួលប្រមូល និងដឹកជញ្ជូនសំណល់រឹង-សំរាម ដូចបានចែងក្នុងចំនុចទី ១ ( ក )។

ខ- ក្រុមហ៊ុន សារ៉ុ ត្រេឌីង កូ អេលធីឌី និងរដ្ឋាករស្វយ័តគ្រប់គ្រងសំណល់ក្រុង ទទួលប្រមូល និងដឹកជញ្ជូនតែសំណល់រឹងឧស្សាហកម្ម ដូចបានចែងក្នុងចំនុចទី ១ ( ខ ) ចំពោះរោងចក្រដែលមានទីតាំងទីតាំងក្នុងរាជធានីភ្នំពេញ ។

គ- ក្រុមហ៊ុន សារ៉ុ ត្រេឌីង កូ អេលធីឌី ទទួលប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហកម្ម ដូចបានចែងក្នុងចំនុចទី ១ ( ខ ) ចំពោះរោងចក្រ- សហគ្រាសដែលមានទីតាំងនៅក្នុងខេត្តកណ្តាល ។

៤. រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ត្រូវសុំលិខិតអនុញ្ញាតបញ្ចេញសំណល់រឹងប្រភេទ ១ ( ខ ) ពីក្រសួងបរិស្ថាន មុនប្រគល់ឱ្យក្រុមហ៊ុនធ្វើការប្រមូល និងដឹកជញ្ជូនយកទៅចាក់ចោល ។

៥. ហាមឃាត់ដាច់ខាត ការលួចបួមសំណល់ភក់អាងប្រព្រឹត្តកម្មសំអាតសំណល់រាវដោយរថយន្តបូមលួយកទៅបញ្ចេញចោលនៅកន្លែងដែលមិនមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

ទទួលបាននូវសេចក្តីណែនាំនេះ ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ-សហគ្រាស និងក្រុមហ៊ុនទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ ក្នុងករណីប្រព្រឹត្តល្មើសទៅនឹងសេចក្តីណែនាំនេះ ក្រសួងបរិស្ថាន នឹងអនុវត្តតាមវិធានការច្បាប់ ។

រដ្ឋមន្ត្រី

ក្រសួង បរិស្ថាន

ម៉ុក មារ៉េត

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានខេត្តកណ្តាល
- ឯកសារ

# សេចក្ដីណែនាំ

## ស្ដីពី

## ការគ្រប់គ្រងសំណល់ភក់នៅតាម
## រោងចក្រ-សហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: 177 ប.ស្ក ៩៩៥

រាជធានីភ្នំពេញ. ថ្ងៃទី ០៩ ខែ ១៣ ឆ្នាំ ២០០០

## សេចក្តីណែនាំ

### ស្តីពី ការគ្រប់គ្រងសំណល់ភក់នៅតាមរោងចក្រ-សហគ្រាស

**យោង** : - ព្រះរាជក្រមលេខ នស/ រកម/ ១២៩៦/ ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

- អនុក្រឹត្យលេខ ២៧ អនក្រ/ បក ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។
- អនុក្រឹត្យលេខ ៣៦ អនក្រ/ បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពី ការគ្រប់គ្រងសំណល់រឹង។

ដោយពិនិត្យឃើញថា នៅតាមបណ្តារោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ ការគ្រប់គ្រងនូវសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួន គឺមានលក្ខណៈពុំទាន់សមស្របទៅតាមលក្ខណៈបច្ចេកទេស ដែលអាចធានាបាននូវសុវត្ថិភាពបរិស្ថាន ហើយកន្លងមកនេះ មានរោងចក្រមួយចំនួនបានបូម ឬស្តារសំណល់ភក់ទាំងនោះ ដឹកយកទៅចាក់ចោលនៅតាមទីវាល និងតំបន់ទីកសាធារណៈ ដែលជាហេតុបង្កអោយមានការបំពុលបរិស្ថាន និងប៉ះពាល់ទៅដល់សុខភាពសាធារណៈនាពេលបច្ចុប្បន្ននិងទៅអនាគត ។

ដើម្បីជំរុញការគ្រប់គ្រងសំណល់ភក់នៅតាមបណ្តារោងចក្របោកគក់ ឱ្យមានលក្ខណៈសមស្របទៅតាមលក្ខណៈបច្ចេកទេសសុវត្ថិភាពបរិស្ថាន ដែលអាចធានានូវការទប់ស្កាត់និងកាត់បន្ថយការបំពុលបរិស្ថាន និងការពារសុខភាពសាធារណៈ ក្រសួងបរិស្ថានសូមធ្វើការណែនាំដល់បណ្តារោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ទាំងអស់ ដូចខាងក្រោម :

១ - ត្រូវធ្វើការផ្តល់ដំណឹងជូនមកក្រសួងបរិស្ថានជាមុន ក្នុងករណីដែលរោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ មានគំរោងធ្វើការស្តារសំណល់ភក់ចេញពីអាងស្តុក ឬអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួន ។

២ - ត្រូវធ្វើការហាល ឬគៀបសំងួតសំណល់ភក់ នៃអាងស្តុកនិងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ពោកគក់ និងត្រូវធ្វើការស្តុកទុកជាបណ្តោះអាសន្នឱ្យបានសមស្រប ជៀសវាងការប៉ះពាល់ដល់គុណភាពបរិស្ថាននិងសុខភាពសាធារណៈ ។

៣ - ត្រូវធ្វើរបាយការណ៍ពីបរិមាណស្តុកនៃសំណល់ភក់ និងទីតាំងស្តុក មកក្រសួងបរិស្ថានរៀងរាល់បីខែម្តង ។

៤ - ហាមឃាត់ជាដាច់ខាតការចាក់ចោល ឬដឹកសំណល់ភក់លាយឡំជាមួយសំណល់រឹងលំនៅស្ថាន។

៥ - ហាមឃាត់ជាដាច់ខាតការបូមសំណល់ភក់ នៃអាងស្តុកនិងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ពោកគក់ យកទៅចាក់ចោលនៅតាមលូសាធារណៈ ឬតំបន់ទឹកសាធារណៈ ។

៦ - ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការដឹកជញ្ជូនសំណល់ភក់ស្ងួតយកចេញពីទីតាំងរោងចក្រ-សហគ្រាស ទៅកាន់ទីដីនៃក្នុងគោលបំណងណាមួយ ។

ទទួលបានសេចក្តីណែនាំនេះ ម្ចាស់រោងចក្រ-សហគ្រាសពោកគក់សំលៀកបំពាក់ទាំងអស់ត្រូវខិតខំអនុវត្តការគ្រប់គ្រងសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួនប្រកបដោយប្រសិទ្ធខ្ពស់ ។ ក្នុងករណីមិនអនុវត្តតាម ឬអនុវត្តផ្ទុយទៅនឹងចំនុចណាមួយនៃសេចក្តីណែនាំខាងលើ ក្រសួងបរិស្ថាននឹងចាត់វិធានការតាមផ្លូវច្បាប់ ។

រដ្ឋមន្ត្រី

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- សាលាខេត្ត-ក្រុង

"<u>ដើម្បីជូនជ្រាបជាព័តមាន</u>"

- អគ្គនាយកដ្ឋាន
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

"<u>ដើម្បីមុខការ</u>"

- មន្ទីរបរិស្ថានខេត្ត-ក្រុង "<u>ដើម្បីសហការតាមដានការអនុវត្តន៍</u>"
- ឯកសារ កាលប្បវត្តិ

# សេចក្ដីណែនាំ

# ស្ដីពី

# ស្ដីអំពីតួនាទី និងភារកិច្ច
# របស់មន្ត្រីរាជការប្រចាំការខុទ្ទកាល័យរដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងគ្រប់គ្រងបរិស្ថាន

លេខ: 1315 ប.ស្ល.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ 7 ឆ្នាំ១៩៩5

# សេចក្តីណែនាំ

## ស្តីអំពីតួនាទីនិងភារកិច្ច
## របស់មន្ត្រីរាជការប្រចាំការឧទ្យានជាតិ

អនុវត្តព្រះរាជក្រឹត្យចុះថ្ងៃទី 1 ខែ វិច្ឆិកា ឆ្នាំ 1993 និងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការថែរក្សាការពារតំបន់ការពារធម្មជាតិ ក្រសួងគ្រប់គ្រងបរិស្ថាន បានដំណើរការរៀបចំផែនការគ្រប់គ្រង ឧទ្យានជាតិព្រះសីហនុ ឧទ្យានជាតិព្រះសុរាម្រិតកុសុមៈ (គិរីរម្យ) និងបន្តការរៀបចំផែនការ ដែនការពារធម្មជាតិផ្សេងៗទៀត ។

ដើម្បីមានមូលដ្ឋាន ក្នុងការគ្រប់គ្រងថែរក្សាការពារ និងដំណើរការឧទ្យានជាតិបានល្អប្រសើរ ទោះអនាគត ក្រសួងគ្រប់គ្រងបរិស្ថាន សូមធ្វើការណែនាំពីតួនាទី និងភារកិច្ចរបស់មន្ត្រីរាជការ ដែលប្រចាំការនៅឧទ្យានជាតិ ដូចតទៅ :

1- សិក្សាស្វែងយល់អំពីស្ថានភាពភូមិសាស្ត្រ និងកំណត់ទីតាំងព្រំប្រទល់ឧទ្យានជាតិឱ្យបានច្បាស់លាស់ ។

2- សិក្សាស្រាវជ្រាវប្រមូលទិន្នន័យ (ប្រភេទសត្វ រុក្ខជាតិ ក្នុងតំបន់ឧទ្យានជាតិ និងធ្វើបញ្ជីសារពើភ័ណ្ឌ )។

3- សិក្សាស្រាវជ្រាវអំពីសក្តានុពលភាព ធ្វើការបែងចែក និងកំណត់តំបន់ឱ្យបានច្បាស់លាស់ ដើម្បីអភិរក្ស និងអភិវឌ្ឍន៍ ។

4- ធ្វើការសិក្សាស្រាវជ្រាវឡើងវិញ នូវរាល់បណ្តាប្រពន្ធ័ផ្លូវនៅតំបន់ឧទ្យានជាតិ ។

5- សិក្សាស្វែងយល់ឱ្យបានស៊ីជំរៅលើផ្នែកធម្មជាតិ និងមានទេពកោសល្យ ក្នុងការបកស្រាយធម្មជាតិ ។

6- ត្រូវសហការណ៍ និងសំរបសំរួលការងារយ៉ាងជិតស្និត ជាមួយកងកំលាំងប្រដាប់អាវុធ នគរបាលជាតិ រដ្ឋអំណាចមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងប្រជាជនមូលដ្ឋានក្នុងការការពារធម្មជាតិ ។

7- សិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ចសង្គមរបស់ប្រជាជននៅក្នុង ឬនៅជុំវិញតំបន់ ដែលមានឥទ្ធិពល មកលើឧទ្យានជាតិ ។



លេខ ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ 27894 / 015 914 055 ទូរសារ 855 23 27844

8- ត្រូវសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចុះយាមល្បាតត្រួតពិនិត្យភាពអនាធិបតេយ្យ ដូចជាការកាប់បំផ្លាញព្រៃឈើ ការបរបាញ់សត្វព្រៃគ្រប់ប្រភេទ ការធ្វើអាជីវកម្មអនុផលព្រៃឈើ ការកាប់ឆ្ការព្រៃ ដើម្បីយកដីមកធ្វើជាកម្មសិទ្ធ ឬប្រកបរបរផ្សេងៗទៀត ។ល។ និង ។ល។

9- ក្នុងករណីដែលជួបប្រទះនូវភាពអនាធិបតេយ្យដោយប្រការណាមួយ ដូចមានចែងក្នុងចំណុច 8 ក្រុមបេសកកម្ម ត្រូវអនុវត្តៈ

- ធ្វើការពន្យល់ ណែនាំ និងអប់រំដល់ជនល្មើស
- សហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីឃាត់ទុកវត្ថុតាងទាំងឡាយ និងធ្វើបែបបទបញ្ជូនសំណុំលិខិតមកថ្នាក់ដឹកនាំក្រសួង ដើម្បីមានវិធានការណ៍ដោះស្រាយ ។

10- ត្រូវមានការយល់ដឹង ពីបទបញ្ញាឧទ្យានជាតិ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ឧទ្យានជាតិ ព្រមទាំងភ្ញៀវទេសចរណ៍ ដែលមកទស្សនាឧទ្យានជាតិ ។

11- ត្រូវធានាសុវត្ថិភាព និងបង្កភាពរីករាយដល់ភ្ញៀវទេសចរណ៍ ដែលចូលទស្សនា (ត្រូវដាក់ផ្លាកសញ្ញា បង្ហាញពីកន្លែង ដែលមានគ្រោះថ្នាក់ និងកន្លែងដែលត្រូវចូលទស្សនា ) ។

12- ត្រូវមានទំនាក់ទំនងល្អជាមួយភ្ញៀវទេសចរណ៍ និងទំនាក់ទំនងជាមួយបណ្តា អ្នកសារពត៌មាន ក្នុងនិងក្រៅប្រទេស វិទ្យុ ទូរទស្សន៍ កាសែត ។ល។ ដើម្បីឱ្យផ្សព្វផ្សាយ អំពីសក្តានុពលភាព នៃឧទ្យានជាតិ ។

13- ត្រួតពិនិត្យ និងមានវិធានការណ៍ទប់ស្កាត់នូវភ្លើងឆេះព្រៃ ។

14- ជារៀងរាល់ដំណាច់ខែ ត្រូវធ្វើរបាយណ៍ពីសកម្មភាពការងារដែលអនុវត្តបាន និងពត៌មានផ្សេងៗដែលទទួលបាន ពីការចុះពិនិត្យអង្កេតសភាពការណ៍ ដែលកើតមានឡើងក្នុងឧទ្យានជាតិ ព្រមទាំងធ្វើទិសដៅផែនការ បញ្ជូនមកក្រសួងគ្រប់គ្រងបរិស្ថាន "នាយកដ្ឋានការពារអភិរក្សធម្មជាតិ" ជារៀងរាល់ថ្ងៃទី 25 នៃខែនីមួយៗ ។

នាយកដ្ឋានការពារអភិរក្សធម្មជាតិ មន្ទីរគ្រប់គ្រងបរិស្ថានខេត្ត-ក្រុង ដែលមានតំបន់ការពារធម្មជាតិ មានភារកិច្ចអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ
- ចំណុចចុងក្រោយ
- ឯកសារ

បណ្ឌិត ម៉ុក-ម៉ារ៉េត

File:Dept.\sei..\Kalyan

# សេចក្តីជូនដំណឹង

# ស្តីពី

# ការបញ្ឈប់ការលក់ ឬ ផ្តល់
# និងការដុតសំណល់រឹងឧស្សាហកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ ០១២ សជណ.ប.ស្ល

រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបញ្ឈប់ការលក់ ឬ ផ្តល់ និងការដុតសំណល់រឹងឧស្សាហកម្ម

ក្រសួងបរិស្ថាន សូមជំរាបជូនដល់ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រកាត់ដេរសំលៀកបំពាក់ទាំងអស់ឱ្យបានជ្រាបថា ដោយពិនិត្យឃើញក្នុងរយៈកាលកន្លងមក មានរោងចក្រមួយចំនួនបានលក់សំណល់រឹងចេញពីរោងចក្រ ជាពិសេសសំណល់ប្រភេទកំទេចក្រណាត់ និងអំបោះទៅឱ្យអ្នកម៉ៅការ ឬ អ្នកទទួលទិញមួយចំនួនដើម្បីយកសំណល់កំទេចក្រណាត់ទាំងនោះទៅធ្វើការកែច្នៃជាសំភារៈប្រើប្រាស់ផ្សេងៗ ។ ផ្ទុយទៅវិញ អ្នកទទួលទិញទាំងនោះ បានយកសំណល់កំទេចក្រណាត់ទៅលក់បន្តឱ្យម្ចាស់អាជីវកម្ម និងសិប្បកម្មមួយចំនួនសំរាប់ដុត ជាហេតុធ្វើឱ្យមានការបំពុលខ្យល់អាកាសដោយផ្សែងដែលភាយចេញពីការដុតកំទេចក្រណាត់ទាំងនោះ បង្កផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋដែលរស់នៅជុំវិញមូលដ្ឋានផលិតកម្ម ។

ដូចនេះ ដើម្បីធានាបាននូវសុវត្ថិភាពបរិស្ថាន និងសុខភាពសាធារណៈ ក្រសួងបរិស្ថានសូមធ្វើការណែនាំដល់ម្ចាស់រោងចក្រ សហគ្រាស និងក្រុមហ៊ុនទាំងអស់ដូចតទៅ:

១. ហាមឃាត់ដាច់ខាតការលក់សំណល់រឹងឧស្សាហកម្ម ( កំទេចក្រណាត់ អំបោះ ប្លាស្ទិក... ) ទៅឱ្យអ្នកម៉ៅការឯកជន ឬ អ្នកទទួលទិញដែលគ្មានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

២. ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ សហគ្រាស និងក្រុមហ៊ុនទាំងអស់ ត្រូវប្រគល់សំណល់រឹងឧស្សាហកម្មរបស់ខ្លួនទៅឱ្យក្រុមហ៊ុន ដែលមានលិខិតអនុញ្ញាតឱ្យប្រមូល ដឹកជញ្ជូន និងយកទៅចាក់ចោលដែលចេញដោយក្រសួងបរិស្ថាន ដូចបានកំណត់នៅក្នុងប្រកាសលេខ ១៤៨ ប្រក.បស្ថ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០២ ។

លេខ ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ : ០២៣ ២១៣ ៩០៦ . ទូរសារ : ៨៥៥ ២៣ ២១ ២៥ ៤០

៣. ការកែច្នៃសំណល់កំទេចក្រណាត់ ឬ សំណល់រឹងឧស្សាហកម្មដទៃទៀត ចាំបាច់ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន ។

៤. ហាមឃាត់ដាច់ខាតការដុតសំណល់រឹងឧស្សាហកម្ម (សំណល់កំទេចក្រណាត់ អំបោះ ប្លាស្ទិក...) នៅកណ្តាលវាលក្នុងនិងក្រៅបរិវេណរោងចក្រ ដោយគ្មានការអនុញ្ញាតពីក្រសួងបរិស្ថាន ។ ក្នុងករណី ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ សគ្រាស និងក្រុមហ៊ុន មានបំណងសាងសង់ឡដុតសំណល់រឹងឧស្សាហកម្មនៅក្នុងបរិវេណរោងចក្រ ដើម្បីយកថាមពលកំដៅទៅប្រើប្រាស់ក្នុងចង្វាក់ផលិតកម្មរបស់រោងចក្រ ត្រូវមកដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន ។ ចំពោះរោងចក្រដែលបាន និងកំពុងដំណើរការឡមានស្រាប់ ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ ត្រូវផ្តល់របាយការណ៍ពីការប្រើប្រាស់ឡនោះមកក្រសួងបរិស្ថានក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយទទួលបានសេចក្តីជូនដំណឹងនេះ ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ-សហគ្រាស និងក្រុមហ៊ុនទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ ក្នុងករណីប្រព្រឹត្តល្មើសទៅនឹងសេចក្តីជូនដំណឹងនេះ ក្រសួងបរិស្ថាននឹងអនុវត្តតាមវិធានការច្បាប់ ។

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានខេត្តកណ្តាល
- ឯកសារ

# សេចក្ដីជូនដំណឹង

# ស្ដីពី

# ការចុះត្រួតពិនិត្យការបំពុលទឹក

# នៅតាមប្រភពបំពុលក្នុងរាំងខេត្ត~ក្រុង

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខ: 141 ស.ជ.ណ.ប.ស្ថ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ. ថ្ងៃទី 04 ខែ 07 ឆ្នាំ ២០០1

# សេចក្តីជូនដំណឹង
## ស្តីពី ការចុះត្រួតពិនិត្យការបំពុលទឹកនៅតាមប្រភពបំពុលទូទាំងខេត្ត-ក្រុង

យោង : - ព្រះរាជក្រមលេខ នស/ រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។
- អនុក្រឹត្យលេខ ២៧ អនក្រ / បក ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។

ដោយពិនិត្យឃើញថា នៅតាមបណ្តារោងចក្រ-សហគ្រាសបោកគក់និងជ្រលក់ពណ៌សំលៀកបំពាក់ និងបណ្តាប្រភពបំពុលដ៏ទៃទៀត ការគ្រប់គ្រងសំណល់រាវនៃអាងស្តុកនិងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួនពុំទាន់បានសមស្របទៅតាមលក្ខណៈបច្ចេកទេស ដែលជាហេតុបង្កឱ្យមានការបំពុលបរិស្ថាននិងប៉ះពាល់ទៅដល់សុខភាពសាធារណៈ ។

ដើម្បីជំរុញការងារត្រួតពិនិត្យការបញ្ចេញសំណល់រាវនៅតាមរោងចក្រ-សហគ្រាសបោកគក់ឱ្យបានសមស្របទៅតាមលក្ខណៈបច្ចេកទេស និងធានាបាននូវការទប់ស្កាត់ឬកាត់បន្ថយការបំពុលបរិស្ថាននិងការការពារសុខភាពសាធារណៈ ក្រសួងបរិស្ថានសូមជូនដំណឹងដល់បណ្តាម្ចាស់រោងចក្រ-សហគ្រាសបោកគក់និងជ្រលក់ពណ៌សំលៀកបំពាក់ទាំងអស់ជ្រាបថា ក្រសួងបរិស្ថាននឹងពង្រឹងការត្រួតពិនិត្យដូចខាងក្រោមនេះ :

១ - ការត្រួតពិនិត្យការបញ្ចេញសំណល់រាវ ព្រមទាំងការយកសំណាកនៅតាមបណ្តារោងចក្រ-

សហគ្រាសបោកគក់ និងរោងចក្រជ្រលក់ពណ៌ នឹងប្រព្រឹត្តទៅក្នុង រយៈពេល ៤៥ ថ្ងៃម្តង ។

២ - ការត្រួតពិនិត្យការបញ្ចេញសំណល់រាវនៅតាមបណ្តារោងចក្រ-សហគ្រាស ក្រុមហ៊ុន សណ្ឋាគារ មន្ទីរពេទ្យ ភោជនីយដ្ឋាន នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃម្តង ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ ម្ចាស់កម្មសិទ្ធិទាំងអស់ត្រូវចូលរួមសហការនិង បង្កលក្ខណៈងាយស្រួលដើម្បីឱ្យការត្រួតពិនិត្យការបញ្ចេញសំណល់រាវរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

ក្នុងករណីមិនប្រតិបត្តិតាម ឬប្រតិបត្តិផ្ទុយទៅនឹងចំនុចណាមួយនៃសេចក្តីជូនដំណឹង ខាងលើនេះ ក្រសួងបរិស្ថាននឹងចាត់វិធានការតាមផ្លូវច្បាប់ ។

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាបជាពត៌មាន"

- អគ្គនាយកដ្ឋាន
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

"ដើម្បីមុខការ"

- មន្ទីរបរិស្ថានខេត្ត-ក្រុង "ដើម្បីសហការតាមដានការអនុវត្តន៍"
- ឯកសារ កាលប្បវត្តិ

# សារាចរណែនាំ

## ស្តីពី

## ការប្រមូលថ្លៃវិភាគរបស់មន្ទីរពិសោធន៍ក្រសួងបរិស្ថាន

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខ: ១៤០ ប.ស្ថ/ប.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ. ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២

# សារាចរណែនាំ

## ស្តីពី

## ការប្រមូលថ្លៃវិភាគរបស់មន្ទីរពិសោធន៍ក្រសួងបរិស្ថាន

ដោយពិនិត្យឃើញថា រយៈពេលកន្លងមកម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសមួយចំនួនបានមកបង់ថ្លៃវិភាគសំណាកសំណល់រឹង-រាវមានការយឺតយ៉ាវ ដែលជាហេតុនាំឱ្យក្រសួងបរិស្ថានប្រមូលចំណូលបង់ចូលថវិការដ្ឋពុំបានទាន់ពេលវេលា ។ ដូចនេះ ដើម្បីជំរុញការប្រមូលថ្លៃវិភាគសំណាកសំណល់រឹង-រាវផ្ទេរបញ្ចូលទៅក្នុងថវិការដ្ឋអោយទាន់ពេលវេលា ដោយផ្អែកលើព្រះរាជក្រមលេខនស/ រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យលេខ ២៧ អនក្រ / បក ចុះថ្ងៃទី ៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យការបំពុលទឹក អនុក្រឹត្យលេខ ៣៦ អនក្រ/បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងសំណល់រឹង និងប្រកាសអន្តរក្រសួងលេខ ៤៧៦ សហវ /បស្ថ / ប្រក ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់ថ្លៃវិភាគសំណល់សំរាប់មន្ទីរពិសោធន៍ក្រសួងបរិស្ថាន ក្រសួងបរិស្ថានសូមធ្វើការណែនាំដល់ម្ចាស់ប្រភពបំពុលរោងចក្រ សហគ្រាសទាំងអស់ ដូចខាងក្រោម:

១-ការបង់ថ្លៃវិភាគសំណាកសំណល់រឹង-រាវ ត្រូវធ្វើនៅការិយាល័យផែនការស្ថិតិ នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ទៅតាមតារាងថ្លៃវិភាគដែលភ្ជាប់មកជាមួយព្រឹត្តិប័ត្រវិភាគ ។

២-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសត្រូវមកបង់ថ្លៃវិភាគយ៉ាងយូរ ១៥ថ្ងៃ ក្រោយទទួលបាននូវព្រឹត្តិប័ត្រវិភាគ និងតារាងថ្លៃវិភាគ ។

៣-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសណា ដែលពុំបានមកបង់ប្រាក់ថ្លៃវិភាគតាមពេលកំណត់ខាងលើ ក្រសួងបរិស្ថាននឹងធ្វើការពិន័យជាទឹកប្រាក់ **ទ្វេរដង** ទៅនឹងទឹកប្រាក់សរុបដែលមាននៅក្នុងតារាងតំលៃវិភាគ។

៤-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសណា ដែលពុំបានមកបង់ប្រាក់ថ្លៃវិភាគក្រោយរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលនូវព្រឹត្តិប័ត្រនិងតារាងថ្លៃវិភាគ ក្រសួងបរិស្ថាននឹងធ្វើការពិន័យជាទឹកប្រាក់ **១.០០០.០០០៛ (មួយលានរៀល)** បន្ថែមទៅលើតំលៃវិភាគ។

ក្រោយទទួលបានសារាចរណែនាំនេះ ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសទាំងអស់ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។ ក្នុងករណីមិនអនុវត្ត រឺប្រព្រឹត្តល្មើសទៅនឹងចំណុចណាមួយនៃសេចក្តីណែនាំខាងលើ ក្រសួងបរិស្ថាននឹងចាត់វិធានការតាមផ្លូវច្បាប់ ។

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

"ដើម្បីជូនជ្រាបជាពតិមាន"

- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

"ដើម្បីមុខការ"

- ឯកសារ -កាលប្បវត្តិ